ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

លេខ...០០៣.........អ.ស.ហ.ប្រក

# ប្រកាស

## ស្តីពី

## វិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច

*****

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០២ ចុះថ្ងៃទី២ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីបរធនបាលកិច្ច
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម
- បានឃើញអនុក្រឹត្យលេខ ៤៧៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ ស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០១៩ ស្តីពីការចុះបញ្ជីបរធនបាលកិច្ច
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនិយ័តករនិងអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- យោងតាមការអនុម័តនៃសម័យប្រជុំរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ នាថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២១

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

### ប្រការ១ .- គោលបំណង និងគោលដៅ

ប្រកាសនេះមានគោលបំណងកំណត់អំពីវិធាន លក្ខខណ្ឌ និងនីតិវិធី ក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅនៃបរធនបាលកិច្ច រួមមាន ការបង្កើត ការចុះបញ្ជីបរធនបាលកិច្ច កិច្ចដំណើរការ ព្រមទាំងការផ្តល់អាជ្ញាបណ្ណ និង/ឬការអនុញ្ញាតដល់ប្រតិបត្តិករបរធនបាល តាមរយៈការកំណត់សិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវក្រោមលក្ខខណ្ឌអាជ្ញាបណ្ណ និង/ឬការអនុញ្ញាតនោះ។

### ប្រការ២ .- វិសាលភាព

ប្រកាសនេះមានវិសាលភាពអនុវត្ត ចំពោះប្រតិបត្តិករបរធនបាលកិច្ច និងសកម្មភាពបុគ្គលពាក់ព័ន្ធក្នុងព្រះរាជាណាចក្រកម្ពុជា។

### ប្រការ៣ .- និយមន័យ

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងប្រកាសនេះ ត្រូវបានកំណត់ក្នុងប្រកាសនេះ និងក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីបរធនបាលកិច្ច។

**ការចាប់ផ្តើមប្រតិបត្តិការបរធនបាលកិច្ច** សំដៅដល់ការចាប់ផ្តើមធ្វើប្រតិបត្តិការរបស់បរធនបាលក្រោយពីទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត/ការចុះបញ្ជី ដោយគិតចាប់ពីពេលដែលបរធនបាលចាប់ផ្តើមជួលបុគ្គលិក ដើម្បីបំពេញការងារសម្រាប់ប្រតិបត្តិការដែលទទួលបានការអនុញ្ញាត/ការចុះបញ្ជី ឬចាប់ពីពេលដែលបរធនបាលចាប់ផ្តើមធ្វើសកម្មភាពពេលដែលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាត។

**ការទទួលកាន់កាប់បន្ត (Takeover)** សំដៅដល់ការសម្រេចបាននូវការទិញមូលបត្រកម្មសិទ្ធិ ការទិញធុរកិច្ច ឬទ្រព្យសកម្មរបស់នីតិបុគ្គលណាមួយ ដើម្បីគ្រប់គ្រង និងកាន់កាប់នីតិបុគ្គលនោះ។

**ការរំលាយបញ្ចូលគ្នា (Merger and Acquisition)** សំដៅដល់យុទ្ធសាស្ត្ររបស់ក្រុមហ៊ុន ឬនីតិបុគ្គលក្នុងការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងទិញលក់ ក្នុងគោលបំណងសម្រេចបានកំណើនឆាប់រហ័ស ឬក្នុងគោលបំណងជាក់លាក់ផ្សេងទៀត។

**ក្រុមហ៊ុនបរធនបាល** សំដៅដល់បរធនបាលជានីតិបុគ្គល ដែលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាតពី **គ.ម.ឌ.** ឱ្យធ្វើប្រតិបត្តិការបរធនបាលកិច្ចមួយ ឬច្រើន។

**ទ្រព្យសម្បត្តិបរធនបាលកិច្ច (Trust Property/Trust Asset/Trust Corpus)** សំដៅដល់ទ្រព្យសម្បត្តិ ឬមូលនិធិដែលបានផ្ទេរទៅក្នុងបរធនបាលកិច្ចរួមទាំងផលដែលបានពីទ្រព្យសម្បត្តិ ឬមូលនិធិនោះ។

**បរធន (Trust Fund)** សំដៅដល់ទ្រព្យសម្បត្តិ ឬមូលនិធិដែលបានផ្ទេរទៅឱ្យបរធនបាលចាត់ចែង គ្រប់គ្រង និងថែរក្សា សម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈ តាមលក្ខខណ្ឌដែលកំណត់ដោយលិខិតបរធនបាលកិច្ច ឬបទប្បញ្ញត្តិជាធរមាន។

**បរធនបាល** សំដៅដល់ក្រុមហ៊ុនបរធនបាល ឬបរធនបាលជារូបវន្តបុគ្គល ដែលទទួលសិទ្ធិចាត់ចែងគ្រប់គ្រង និងថែរក្សាបរធនពីបរធនបាលទាយក ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច សម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈ ដោយអនុលោមតាមលិខិតបរធនបាលកិច្ច ឬបទប្បញ្ញត្តិជាធរមាន។

**បរធនបាលកិច្ច** សំដៅដល់កិច្ចការគ្រប់គ្រង និងចាត់ចែងបរធន ដែលផ្តល់ដោយបរធនបាលទាយកសម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈ ដោយអនុលោមតាមលិខិតបរធនបាលកិច្ច ឬបទប្បញ្ញត្តិជាធរមាន។

**បរធនបាលរូបវន្តបុគ្គល** សំដៅដល់រូបវន្តបុគ្គល ដែលទទួលបានអាជ្ញាបណ្ណពី **គ.ម.ឌ.** ឱ្យធ្វើជាបរធនបាលរូបវន្តបុគ្គលនៃក្រុមហ៊ុនបរធនបាល ឬបរធនបាលរូបវន្តបុគ្គលឯករាជ្យ។

**បរធនបាលរូបវន្តបុគ្គលនៃក្រុមហ៊ុនបរធនបាល** សំដៅដល់រូបវន្តបុគ្គល ដែលទទួលបានអាជ្ញាបណ្ណពី **គ.ម.ឌ.** ឱ្យធ្វើជាបរធនបាលរូបវន្តបុគ្គលក្រោមលក្ខខណ្ឌអាជ្ញាបណ្ណ និង/ឬការអនុញ្ញាតរបស់ក្រុមហ៊ុនបរធនបាល។

**បរធនបាលរូបវន្តបុគ្គលឯករាជ្យ** សំដៅដល់រូបវន្តបុគ្គល ដែលទទួលបានអាជ្ញាបណ្ណពី **គ.ម.ឌ.** ឱ្យធ្វើប្រតិបត្តិការបរធនបាលកិច្ចមួយ ឬច្រើន ហើយបរធនបាលរូបវន្តបុគ្គលឯករាជ្យនេះ មិនស្ថិតនៅក្រោមលក្ខខណ្ឌអាជ្ញាបណ្ណ របស់ក្រុមហ៊ុនបរធនបាលណាមួយឡើយ។

**បុគ្គលទទួលស្គាល់គុណវុឌ្ឍិ (Approved Persons)** សំដៅដល់អភិបាល នាយកប្រតិបត្តិ ប្រធានប្រតិបត្តិការ បុគ្គលិកជំនាញផ្នែកច្បាប់ និងគណនេយ្យករមានជំនាញបរធន ដែលទទួលបានការទទួលស្គាល់គុណវុឌ្ឍិពីអគ្គនាយកនៃ **គ.ម.ឌ.**។

**បុគ្គលសាធារណៈ (Public Person)** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលទទួលនីតិសម្បទាជាបុគ្គលសាធារណៈ ក្នុងការធ្វើសកម្មភាព ឬប្រតិបត្តិការណាមួយក្នុងនាមស្ថាប័នសាធារណៈ ឬរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

**ប្រតិបត្តិការបរធនបាលកិច្ច** សំដៅដល់ការធ្វើប្រតិបត្តិការបរធនបាលកិច្ច ដោយបរធនបាល ឬអ្នកចូលរួមដទៃទៀត ទៅតាមប្រភេទបរធនបាលកិច្ច រួមមាន បរធនបាលកិច្ចសាធារណៈ បរធនបាលកិច្ចហិរញ្ញវត្ថុ បរធនបាលកិច្ចពាណិជ្ជកម្ម បរធនបាលកិច្ចសង្គម និងបរធនបាលកិច្ចបុគ្គល។ បរធនបាល ឬអ្នកចូលរួមដទៃទៀតដែលអាចធ្វើប្រតិបត្តិការបរធនបាលកិច្ចទាំងនេះបាន ត្រូវទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត/ការចុះបញ្ជីពី **គ.ម.ឌ.**។

**សំណើទិញផែនដី (Tender Offer)** សំដៅដល់សំណើសុំទិញ ដែលបើកចំហជាសាធារណៈ ដើម្បីទិញមូលបត្រកម្មសិទ្ធិ ឬភាគហ៊ុនរបស់នីតិបុគ្គលណាមួយចាប់ពី ៥ (ប្រាំ) ភាគរយ ឡើងទៅនៃភាគហ៊ុន ឬមូលបត្រកម្មសិទ្ធិ ឬសំណើសុំទិញដែលមានគោលដៅត្រួតត្រាលើនីតិបុគ្គលណាមួយ។

**អត្ថគាហកៈ** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលទទួលផលប្រយោជន៍ពីបរធនបាលកិច្ច។

## ជំពូកទី២
## វិធាននៃការបង្កើតបរធនបាលកិច្ច

**ប្រការ៤ .‒ សកម្មភាពដែលចាត់ទុកថាជាប្រតិបត្តិការបរធនបាលកិច្ច ដែលត្រូវស្នើសុំការអនុញ្ញាតពី ន.ម.ធ.**

សកម្មភាពទាំងឡាយណាដែលមានចរិតលក្ខណៈដូចក្នុងប្រការនេះ ត្រូវចាត់ទុកថាជាប្រតិបត្តិការបរធនបាលកិច្ច ដែលត្រូវទទួលបានការអនុញ្ញាតពី **ន.ម.ធ.**។ សកម្មភាព ដែលចាត់ទុកថាជាប្រតិបត្តិការបរធនបាលកិច្ច មានជាអាទិ៍ ការផ្ទេរទ្រព្យសម្បត្តិរបស់ម្ចាស់ទ្រព្យ (ហៅថាបរធនបាលទាយក ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច) ទៅឱ្យបុគ្គលដទៃ (ហៅថាបរធនបាល) ដើម្បីគ្រប់គ្រង ចាត់ចែង និងថែរក្សាជំនួសសម្រាប់ជាប្រយោជន៍ដល់អ្នកដទៃទៀត (ហៅថាអត្ថគាហកៈ)។

រាល់ការបង្កើតបរធនបាលកិច្ចទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវស្នើសុំបង្កើតជាមុន និងការអនុញ្ញាតចុះបញ្ជីពីអគ្គនាយកនៃ **ន.ម.ធ.** ដោយអនុលោមតាមច្បាប់ស្តីពីបរធនបាលកិច្ច អនុក្រឹត្យស្តីពីការចុះបញ្ជីបរធនបាលកិច្ច អនុក្រឹត្យស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ និងបទប្បញ្ញត្តិពាក់ព័ន្ធដែលមានជាធរមាន និងបញ្ញត្តិនៃប្រកាសនេះ។

**ប្រការ៥ .‒ បរធនបាលទាយក ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច**

បរធនបាលទាយក ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច អាចជារូបវន្តបុគ្គល ឬនីតិបុគ្គលមួយ ឬច្រើន។

បរធនបាលទាយក ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ចមួយ អាចស្នើសុំបង្កើតបរធនបាលកិច្ចច្រើនជាងមួយ ក្នុងប្រភេទដូចគ្នា ឬប្រភេទផ្សេងគ្នា។

បរធនបាលទាយក ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច ដែលមានចំនួនច្រើនជាងមួយ ត្រូវមានកិច្ចព្រមព្រៀងរួមគ្នាក្នុងការយល់ព្រមបង្កើតបរធនបាលកិច្ច ព្រមទាំងស្នើសុំ និងទទួលបានការអនុញ្ញាតបង្កើតជាមុនពី **ន.ម.ធ.**។

**ប្រការ៦ .‒ អត្តសញ្ញាណរបស់អត្ថគាហកៈ**

បរធនបាលទាយក ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច ដោយមានជំនួយពីបរធនបាល ត្រូវកំណត់ជាក់លាក់នូវអត្ថគាហកៈនៅក្នុងលិខិតបរធនបាលកិច្ច ហើយត្រូវផ្តល់ឱ្យ**ន.ម.ធ.** នូវព័ត៌មាន និងការកំណត់អត្តសញ្ញាណរបស់អត្ថគាហកៈ ដោយត្រូវមានលក្ខណៈពិតប្រាកដ ច្បាស់លាស់ មិនក្លែងបន្លំ ព្រមទាំងមិនពាក់ព័ន្ធនឹងសកម្មភាពលាងសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

**ប្រការ៧ .‒ ប្រភេទបរធនបាលកិច្ច**

បរធនបាលទាយក ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ចអាចស្នើសុំបង្កើតបរធនបាលកិច្ចនូវប្រភេទមួយ ឬច្រើន ដូចមានបញ្ញត្តលម្អិតក្នុងមាត្រា១០ មាត្រា១១ មាត្រា១២ និងមាត្រា១៣ នៃច្បាប់ស្តីពីបរធនបាលកិច្ច ទៅតាមប្រភេទដូចខាងក្រោម÷

-បរធនបាលកិច្ចសាធារណៈ

-បរធនបាលកិច្ចហិរញ្ញវត្ថុ

-បរធនបាលកិច្ចពាណិជ្ជកម្ម

-បរធនបាលកិច្ចសង្គម

-បរធនបាលកិច្ចបុគ្គល។

## ប្រការ៨ .- ការតែងតាំងបរធនបាល

ដើម្បីទទួលបានការអនុញ្ញាតបង្កើត និងការចុះបញ្ជីបរធនបាលកិច្ច បរធនបាលទាយក ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច ត្រូវធ្វើការជ្រើសរើសបេក្ខភាពបរធនបាលដែលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាតពី **ន.ម.ធ.**។ បន្ទាប់ពីទទួលបានការអនុញ្ញាតជាស្ថាពរភ្លាមពីអគ្គនាយកនៃ **ន.ម.ធ.** បរធនបាល ដែលត្រូវបានអនុញ្ញាតតែងតាំង ត្រូវបន្តនីតិវិធីស្នើសុំបង្កើតបរធនបាលកិច្ចក្នុងនាមបរធនបាលទាយក ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ចក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការអនុញ្ញាតនោះ។

បរធនបាលទាយក ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច អាចតែងតាំងបរធនបាលមួយ ឬច្រើន សម្រាប់បរធនបាលកិច្ចមួយស្របតាមមាត្រា២០ នៃច្បាប់ស្តីពីបរធនបាលកិច្ច។ ការតែងតាំងបរធនបាលជារូបវន្តបុគ្គលច្រើនជាងមួយ បរធនបាលនោះត្រូវតែជាចំនួនសេស។

ប្រការនេះ មិនអនុវត្តចំពោះបរធនបាលកិច្ច ដែលបង្កើតឡើងដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានោះទេ។

## ប្រការ៩ .- លិខិតបរធនបាលកិច្ច

បរធនបាលកិច្ច ត្រូវបានចងលក្ខខណ្ឌដោយលិខិតបរធនបាលកិច្ច និងការព្រមព្រៀងរួមគ្នារវាងបរធនបាលទាយក ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច និងបរធនបាល។

លិខិតបរធនបាលកិច្ច ត្រូវមាននិទ្ទេសអប្បបរមាដូចមានចែងក្នុងមាត្រា៦ នៃអនុក្រឹត្យស្តីពីការចុះបញ្ជីបរធនបាលកិច្ច និងមានទម្រង់កំណត់ដោយ **ន.ម.ធ.**។

លក្ខខណ្ឌ ឬខចែងនៃលិខិតបរធនបាលកិច្ច ដែលមិនចាត់ទុកថាមានសុពលភាព និងមិនត្រូវបានអនុញ្ញាតឱ្យចែងនូវ÷

១-ការរួចពីការទទួលខុសត្រូវ ចំពោះការរំលោភបំពានណាមួយលើបរធនបាលកិច្ចរបស់បរធនបាលដែលកើតចេញពីភាពមិនស្មោះត្រង់ មិនសុចរិត ដោយចេតនា ឬការធ្វេសប្រហែសធ្ងន់ធ្ងររបស់បរធនបាលនោះ។

២-ការយកទ្រព្យសម្បត្តិបរធនបាលកិច្ចទៅធ្វើការទូទាត់សំណង ឬមុខចំណាយណាមួយ ដែលទាក់ទងនឹងការទទួលខុសត្រូវរបស់បរធនបាល ចំពោះការបំពានណាមួយរបស់បរធនបាលលើបរធនបាលកិច្ច ដែលកើតចេញពីភាពមិនស្មោះត្រង់ មិនសុចរិត ដោយចេតនា ឬការធ្វេសប្រហែសធ្ងន់ធ្ងររបស់បរធនបាលនោះ។

៣-ខចែងទាំងឡាយណាដែលមានលក្ខណៈផ្ទុយទៅនឹងសណ្តាប់ធ្នាប់ និងផលប្រយោជន៍សាធារណៈ។

**ប្រការ១០ ._ ការអនុញ្ញាតបង្កើតបរធនបាលកិច្ច**

ក្នុងនាមបរធនបាលទាយក ឬអ្នកផ្ដល់វិភាគទានបរធនបាលកិច្ច បរធនបាលដែលទទួលបានការអនុញ្ញាត និងតែងតាំងរួចរាល់ ត្រូវរៀបចំដាក់ពាក្យស្នើសុំបង្កើតបរធនបាលកិច្ចមក **ន.ម.ធ.** តាមទម្រង់ និងផ្ដល់ឯកសារភ្ជាប់ ដែលកំណត់ដោយអគ្គនាយកនៃ **ន.ម.ធ.**។

អគ្គនាយកនៃ **ន.ម.ធ.** ត្រូវឆ្លើយតបទៅបរធនបាលអំពីការបដិសេធក្នុងការបង្កើត ឬការអនុញ្ញាតជាគោលការណ៍ឱ្យបង្កើតបរធនបាលកិច្ច ក្នុងរយៈពេលមិនលើសពី ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលពាក្យស្នើសុំបង្កើតដោយភ្ជាប់មកជាមួយឯកសារពេញលេញ។

បន្ទាប់ពីទទួលបានការអនុញ្ញាតឱ្យបង្កើតបរធនបាលកិច្ចភ្លាម បរធនបាលត្រូវបន្តនីតិវិធីចុះបញ្ជីបរធនបាលកិច្ច ដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន និងតាមទម្រង់កំណត់ដោយអគ្គនាយកនៃ **ន.ម.ធ.**។

ការស្នើសុំចុះបញ្ជីបរធនបាលកិច្ច បរធនបាលរូបវន្តបុគ្គលនៃក្រុមហ៊ុនបរធនបាល ឬបរធនបាលរូបវន្តបុគ្គលឯករាជ្យ ត្រូវបង្ហាញវត្តមាននៅ **ន.ម.ធ.** ដើម្បីដាក់ពាក្យស្នើសុំចុះបញ្ជីបរធនបាលកិច្ច ស្របតាមបទប្បញ្ញត្តិក្នុងវិស័យបរធនបាលកិច្ច។

**ប្រការ១១ ._ ការបដិសេធលើការស្នើសុំបង្កើតបរធនបាលកិច្ច**

ការស្នើសុំបង្កើតបរធនបាលកិច្ច អាចត្រូវបានបដិសេធដោយអគ្គនាយកនៃ **ន.ម.ធ.** ក្នុងករណីដែលបុគ្គលដាក់ពាក្យស្នើសុំ មិនអាចបំពេញតាមលក្ខខណ្ឌណាមួយដូចមានចែងក្នុងប្រការ៦, ប្រការ៧, ប្រការ៨, ប្រការ៩, ឬប្រការ១០ នៃប្រកាសនេះ។

## ជំពូកទី៣
## វិធាននៃការគ្រប់គ្រងបរធនបាល
## ផ្នែកទី១
## ការផ្ដល់អាជ្ញាបណ្ណ និង/ឬការអនុញ្ញាតធ្វើជាបរធនបាល

**ប្រការ១២ ._ អាជ្ញាបណ្ណ និង/ឬការអនុញ្ញាតធ្វើជាបរធនបាល**

គ្មានបុគ្គលណាមួយតាំងខ្លួន ឬធ្វើសកម្មភាពជាបរធនបាល ឬជាតំណាងបរធនបាល នៅក្នុងព្រះរាជាណាចក្រកម្ពុជាបានទេ លុះត្រាតែបុគ្គលនោះទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត/ការចុះបញ្ជី ពីអគ្គនាយកនៃ **ន.ម.ធ.**។

បុគ្គលសាធារណៈដែលទទួលបានការតែងតាំងពីរាជរដ្ឋាភិបាល ដើម្បីធ្វើប្រតិបត្តិការជាបរធនបាល មិនស្ថិតនៅក្នុងលក្ខខណ្ឌអាជ្ញាបណ្ណ និង/ឬការអនុញ្ញាតនៅក្នុងប្រកាសនេះទេ។

អាជ្ញាបណ្ណ និង/ឬការអនុញ្ញាតធ្វើជាបរធនបាលមានសុពលភាព ២ (ពីរ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញអាជ្ញាបណ្ណ និង/ឬការអនុញ្ញាត។

អាជ្ញាបណ្ណបន្ត និង/ឬការអនុញ្ញាតបន្តរបស់បរធនបាលមានសុពលភាព ៣ (បី) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទអាជ្ញាបណ្ណ និង/ឬការអនុញ្ញាតចាស់អស់សុពលភាព។

**ប្រការ១៣ .- ប្រភេទប្រតិបត្តិការបរធនបាលកិច្ចរបស់បរធនបាល**

បរធនបាលដែលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាត អាចធ្វើប្រតិបត្តិការបរធនបាលកិច្ចមួយ ឬច្រើន ដូចខាងក្រោម÷

១-ប្រតិបត្តិការបរធនបាលកិច្ចសាធារណៈ

២-ប្រតិបត្តិការបរធនបាលកិច្ចហិរញ្ញវត្ថុ

៣-ប្រតិបត្តិការបរធនបាលកិច្ចពាណិជ្ជកម្ម

៤-ប្រតិបត្តិការបរធនបាលកិច្ចសង្គម

៥-ប្រតិបត្តិការបរធនបាលកិច្ចបុគ្គល

៦-ប្រតិបត្តិការបរធនបាលកិច្ចផ្សេងទៀតតាមការកំណត់របស់ **ន.ម.ធ.**។

**ប្រការ១៤ .- សកម្មភាពនៃប្រតិបត្តិការបរធនបាលកិច្ចរបស់បរធនបាល**

បរធនបាលដែលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាត អាចធ្វើប្រតិបត្តិការបរធនបាលកិច្ច ដូចខាងក្រោម÷

- ជាជំនួយដល់បរធនបាលទាយក/អ្នកផ្តល់វិភាគទានបរធនបាលកិច្ច ក្នុងការដាក់ពាក្យស្នើសុំបង្កើតបរធនបាលកិច្ចដំបូង
- ចុះបញ្ជីបរធនបាលកិច្ច តាមលក្ខខណ្ឌច្បាប់ និងបទប្បញ្ញត្តិជាធរមានក្នុងវិស័យបរធនបាលកិច្ច
- គ្រប់គ្រង ចាត់ចែង និងថែរក្សាទ្រព្យសម្បត្តិបរធនបាលកិច្ច សម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈ ឬក្នុងគោលបំណងដែលត្រូវបានអនុញ្ញាតដោយអគ្គនាយកនៃ **ន.ម.ធ.**
- ថែរក្សាសុវត្ថិភាពសាច់ប្រាក់ ឬបរធន ដែលបរធនបាលទាយក/អ្នកផ្តល់វិភាគទានបរធនបាលកិច្ចបានផ្ទេរចូលបរធនបាលកិច្ច តាមរបៀបដូចមានចែងក្នុងលិខិតបរធនបាលកិច្ច ឬបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច
- កាន់កាប់បរធន/ទ្រព្យសម្បត្តិបរធនបាលកិច្ច ដោយអនុលោមតាមលិខិតបរធនបាលកិច្ច និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច
- ធ្វើជាតំណាងនៃភាពជាម្ចាស់កម្មសិទ្ធិស្របច្បាប់លើទ្រព្យសម្បត្តិបរធនបាលកិច្ច
- ទូទាត់ភាគលាភ ការប្រាក់ ឬលាភការផ្សេងៗ ដែលកើតចេញពីទ្រព្យសម្បត្តិបរធនបាលកិច្ច ដោយអនុលោមតាមលិខិតបរធនបាលកិច្ច និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច
- ត្រួតពិនិត្យសេចក្តីណែនាំផ្សេងៗពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិបរធនបាលកិច្ច និងការអនុវត្តផែនការសកម្មភាព ឬគម្រោងពាក់ព័ន្ធនឹងការចាត់ចែងបរធន និងកម្មវិធីផ្សេងៗ ដែលត្រូវបានអនុញ្ញាតដូចក្នុងកម្មវត្ថុនៃលិខិតបរធនបាលកិច្ច ត្រូវបានអនុវត្តត្រឹមត្រូវ

ស.ឋ

-ត្រួតពិនិត្យ និងតាមដានយ៉ាងសកម្ម ព្រមទាំងធានាថា ប្រតិបត្តិការ និងការគ្រប់គ្រងគម្រោងផែនការ និងការទូទាត់ចំណូលទទួលបាន ធ្វើឡើងដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន

-ធ្វើប្រតិបត្តិការផ្សេងទៀត ដែលកំណត់ដោយអគ្គនាយកនៃ **ន.ម.ធ.**។

**ប្រការ១៥ .- ការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ និង/ឬការអនុញ្ញាត និងបន្តអាជ្ញាបណ្ណ និង/ឬបន្តការអនុញ្ញាតធ្វើជាបរធនបាល**

បុគ្គលដែលមានបំណងធ្វើប្រតិបត្តិការជាបរធនបាល ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ និង/ឬការអនុញ្ញាតមក **ន.ម.ធ.** ទៅតាមទម្រង់ និងផ្តល់ឯកសារភ្ជាប់ ដែលកំណត់ដោយអគ្គនាយកនៃ **ន.ម.ធ.**។

ករណីស្នើសុំបន្តអាជ្ញាបណ្ណ និង/ឬបន្តការអនុញ្ញាត បរធនបាលត្រូវដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណ និង/ឬបន្តការអនុញ្ញាតមក **ន.ម.ធ.** ទៅតាមទម្រង់ និងផ្តល់ឯកសារភ្ជាប់ ដែលកំណត់ដោយអគ្គនាយកនៃ **ន.ម.ធ.** ឱ្យបានយ៉ាងតិច ៦០ (ហុកសិប) ថ្ងៃ មុនកាលបរិច្ឆេទអាជ្ញាបណ្ណ និង/ឬការអនុញ្ញាតអស់សុពលភាព។

អគ្គនាយកនៃ **ន.ម.ធ.** ត្រូវចាត់ចែងការចុះត្រួតពិនិត្យដល់ទីកន្លែង ដើម្បីផ្ទៀងផ្ទាត់ពាក្យស្នើសុំអាជ្ញាបណ្ណនិង/ឬការអនុញ្ញាត និងពាក្យស្នើសុំបន្តអាជ្ញាបណ្ណ និង/ឬបន្តការអនុញ្ញាត។

អគ្គនាយកនៃ **ន.ម.ធ.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ដល់បុគ្គលដាក់ពាក្យស្នើសុំអំពីការយល់ព្រម ឬបដិសេធផ្តល់អាជ្ញាបណ្ណ និង/ឬការអនុញ្ញាត ឬបន្តអាជ្ញាបណ្ណ និង/ឬបន្តការអនុញ្ញាត ដូចមានចែងក្នុងកថាខណ្ឌទី១ និងកថាខណ្ឌទី២ នៃប្រការនេះ ក្នុងរយៈពេលយ៉ាងយូរ ៦០ (ហុកសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែល **ន.ម.ធ.** ទទួលបានពាក្យស្នើសុំ និងឯកសារភ្ជាប់ពេញលេញ។

## ផ្នែកទី២
## លក្ខខណ្ឌតម្រូវក្នុងការទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាតធ្វើជាក្រុមហ៊ុនបរធនបាល

**ប្រការ១៦ .- លក្ខខណ្ឌតម្រូវក្នុងការផ្តល់អាជ្ញាបណ្ណ និង/ឬការអនុញ្ញាតធ្វើជាក្រុមហ៊ុនបរធនបាល**

បុគ្គលដែលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ និង/ឬការអនុញ្ញាត ឬបន្តអាជ្ញាបណ្ណ និង/ឬបន្តការអនុញ្ញាតធ្វើជាក្រុមហ៊ុនបរធនបាលត្រូវបំពេញតាមលក្ខខណ្ឌ ដូចខាងក្រោម÷

១- ជាក្រុមហ៊ុនដែលបានបង្កើត និងចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា។

២- ចុះបញ្ជីពន្ធដារអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ។

៣- មានមូលធនអប្បបរមា ទៅតាមប្រភេទនៃបរធនបាលកិច្ច ដូចតទៅ÷

- បរធនបាលកិច្ចសាធារណៈ÷ មានមូលធនអប្បបរមាចំនួន ៦.០០០.០០០.០០០ (ប្រាំមួយប៊ីលាន) រៀល
- បរធនបាលកិច្ចពាណិជ្ជកម្ម÷ មានមូលធនអប្បបរមាចំនួន ៤.០០០.០០០.០០០ (បួនប៊ីលាន) រៀល
- បរធនបាលកិច្ចសង្គម÷ មានមូលធនអប្បបរមាចំនួន ២.០០០.០០០.០០០ (ពីរប៊ីលាន) រៀល
- បរធនបាលកិច្ចបុគ្គល÷ មានមូលធនអប្បបរមាចំនួន ៦០០.០០០.០០០ (ប្រាំមួយរយលាន) រៀល។



ត.ច

បុគ្គលដាក់ពាក្យស្នើសុំធ្វើប្រតិបត្តិការបរធនបាលកិច្ច ដែលកំណត់មូលធនអប្បបរមាខ្ពស់ មិនតម្រូវឱ្យបន្ថែមមូលធនអប្បបរមា សម្រាប់ការស្នើសុំធ្វើប្រតិបត្តិការបរធនបាលកិច្ច ដែលតម្រូវមូលធនអប្បបរមាទាបជាងនោះទេ។ ចំណែកឯបុគ្គលដាក់ពាក្យស្នើសុំធ្វើប្រតិបត្តិការបរធនបាលកិច្ច ដែលមានកម្រិតមូលធនអប្បបរមាទាប ហើយមានបំណងដាក់ពាក្យស្នើសុំធ្វើប្រតិបត្តិការបរធនបាលកិច្ច ដែលមានកម្រិតមូលធនអប្បបរមាខ្ពស់ជាង ត្រូវបន្ថែមមូលធនអប្បបរមាទៅតាមការកំណត់នៃបរធនបាលកិច្ច ដែលខ្ពស់ជាងនោះ។

ក្រុមហ៊ុនបរធនបាលត្រូវដាក់ប្រាក់តម្កល់ធានាអាជីវកម្មចំនួន ១៥ (ដប់ប្រាំ) ភាគរយ នៃមូលធនអប្បបរមារបស់ក្រុមហ៊ុនក្នុងគណនីរបស់ **ន.ម.ឆ.** នៅធនាគារជាតិនៃកម្ពុជា។ ក្រុមហ៊ុនបរធនបាលត្រូវរក្សាឱ្យបានគ្រប់ពេលវេលានូវមូលធនភាគហ៊ុនិកយ៉ាងតិចស្មើនឹងមូលធនអប្បបរមា ដូចមានចែងក្នុងប្រការនេះ។

៤-បំពេញលក្ខខណ្ឌតម្រូវធនធានមនុស្ស ដូចខាងក្រោម÷

ក-មានយ៉ាងហោចណាស់អភិបាលម្នាក់ នាយកប្រតិបត្តិ ប្រធានប្រតិបត្តិការ បុគ្គលិកជំនាញផ្នែកច្បាប់ និងគណនេយ្យករមានជំនាញបរធន ដែលត្រូវទទួលបានការទទួលស្គាល់គុណវុឌ្ឍិពីអគ្គនាយកនៃ **ន.ម.ឆ.** និងបំពេញលក្ខខណ្ឌតម្រូវ ដូចមានចែងនៅក្នុងប្រការ១៧នៃប្រកាសនេះ

ខ-មានបរធនបាលរូបវន្តបុគ្គលនៃក្រុមហ៊ុនបរធនបាល ដែលត្រូវទទួលបានអាជ្ញាបណ្ណ ពីអគ្គនាយកនៃ **ន.ម.ឆ.**។ បុគ្គលដាក់ពាក្យស្នើសុំត្រូវមានបរធនបាលរូបវន្តបុគ្គលដាច់ដោយឡែកពីគ្នាទៅតាមប្រភេទបរធនបាលកិច្ចនីមួយៗ និងត្រូវមានចំនួនបរធនបាលរូបវន្តបុគ្គលឱ្យសមាមាត្រទៅតាមទំហំប្រតិបត្តិការបរធនបាលកិច្ចរបស់ខ្លួន។

៥-មានអភិបាល និងបុគ្គលិកជាន់ខ្ពស់ ដែលមិនជាប់ពាក់ព័ន្ធនឹងចំណុចណាមួយ ដូចខាងក្រោម÷

-ជាអភិបាល ឬជាបុគ្គលិកជាន់ខ្ពស់នៃក្រុមហ៊ុនបរធនបាល ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ និងក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសផ្សេងទៀត

-ធ្លាប់ធ្វើជាអភិបាលរបស់ក្រុមហ៊ុនដែលអាជ្ញាបណ្ណ ឬការអនុញ្ញាតរបស់ក្រុមហ៊ុននោះ ត្រូវបានដកហូតដោយអគ្គនាយកនៃ **ន.ម.ឆ.** ឬដោយស្ថាប័នណាមួយរបស់ប្រទេសផ្សេងទៀត ឬដោយស្ថាប័នមានសមត្ថកិច្ចណាមួយ ដែលមានអំណាចប្រហាក់ប្រហែលនឹង **ន.ម.ឆ.** លើកលែងតែមានការអនុញ្ញាតពីអគ្គនាយកនៃ **ន.ម.ឆ.**

-ធ្លាប់ជាប់ពាក់ព័ន្ធនឹងសកម្មភាពលាងសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

៦-មានអគារ និងបរិវេណ ដែលស្ថិតនៅទីតាំងសមស្រប និងដាច់ដោយឡែកពីអាជីវកម្មផ្សេងទៀត។

៧-មានប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រាន់ ឧបករណ៍ សម្ភារៈជារូបវន្ត ដើម្បីផ្តល់សេវាជាក្រុមហ៊ុនបរធនបាល និងត្រូវដំឡើងឱ្យបានពេញលេញនូវប្រព័ន្ធទ្រទ្រង់ និងប្រព័ន្ធដែលអាចការពារភាពលើសហួសសមត្ថភាព ឬការខូចខាត និងដែលអាចដោះស្រាយរាល់បញ្ហាដែលអាចកើតមាន។

៨-មានវិធានប្រតិបត្តិការដូចមានចែងក្នុងប្រការ១៩ នៃប្រកាសនេះ។

៩-មានផែនការអាជីវកម្មសម្រាប់រយៈពេល ៣ (បី) ឆ្នាំគិតចាប់ពីកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។

១០-មានគោលនយោបាយ សម្រាប់គ្រប់គ្រងហានិភ័យនិងត្រួតពិនិត្យផ្ទៃក្នុង សមស្រប។

១១-មានគោលការណ៍ស្គាល់អតិថិជន។

១២-មានក្រមសីលធម៌វិជ្ជាជីវៈ។

១៣-មានគោលការណ៍អនុវត្ត និងតាមដានសកម្មភាពប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

រាល់បុគ្គលដែលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ និង/ឬការអនុញ្ញាត ឬបន្តអាជ្ញាបណ្ណ និង/ឬបន្តការអនុញ្ញាតធ្វើប្រតិបត្តិការបរធនបាលកិច្ចណាមួយ មិនត្រូវស្ថិតនៅក្រោមករណីដូចខាងក្រោម÷

ក-មិនបានគោរពតាមសេចក្តីណែនាំផ្សេងៗ ដែលធ្វើឡើងដោយអនុលោមតាមប្រកាសនេះ។

ខ-ព័ត៌មាន ឬឯកសារ ដែលបុគ្គលដាក់ពាក្យស្នើសុំបានដាក់ជូន **ន.ម.ធ.** មានលក្ខណៈក្លែងបន្លំ ឬនាំឱ្យយល់ខុស។

គ-ស្ថិតក្នុងស្ថានភាពឈានទៅរកការឈប់ធ្វើអាជីវកម្ម ឬការរំលាយអាជីវកម្ម។

ឃ-មិនទូទាត់សងបំណុលតាមសេចក្តីសម្រេចរបស់តុលាការ។

ង-ធ្លាប់ធ្វើជាភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលុប ឬបុគ្គលដែលមានទំនាក់ទំនងពិសេសជាមួយបរធនបាលទាយកណាមួយ អត្ថគាហកៈណាមួយ ឬគ្រឹះស្ថានហិរញ្ញវត្ថុណាមួយ ដែលធ្លាប់ត្រូវបានប្រកាសក្ស័យធននៅក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជាក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំចុងក្រោយ គិតត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ លើកលែងតែបុគ្គលដែលត្រូវបានទទួលស្គាល់ ដោយសេចក្តីសម្រេចរបស់តុលាការថា ពុំមានការទទួលខុសត្រូវចំពោះការក្ស័យធននេះ។

ច-ធ្លាប់ធ្វើជាភាគហ៊ុនិក ដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលុប ឬបុគ្គលដែលមានទំនាក់ទំនងពិសេសជាមួយបរធនបាលទាយកណាមួយ អត្ថគាហកៈណាមួយ ឬគ្រឹះស្ថានហិរញ្ញវត្ថុ ដែលអាជ្ញាបណ្ណរបស់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ ឬគ្រឹះស្ថានហិរញ្ញវត្ថុនោះត្រូវបានដកហូតនៅក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជាក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ ចុងក្រោយ គិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ លើកលែងតែបុគ្គលដែលត្រូវបានទទួលស្គាល់ថាពុំមានការទទួលខុសត្រូវចំពោះការដកហូតនេះ។

ឆ-ធ្លាប់ជាបុគ្គលជាប់ពាក់ព័ន្ធនឹងនីតិវិធីដូចជា ការក្ស័យធន ឬការជម្រះបញ្ជីនៅក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំចុងក្រោយ គិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។

ជ-ស្ថានភាពហិរញ្ញវត្ថុ ឬវិធីសាស្ត្រធ្វើប្រតិបត្តិការបរធនបាលកិច្ចរបស់បុគ្គលដាក់ពាក្យស្នើសុំ មិនទាន់មានលក្ខណៈគ្រប់គ្រាន់។

ឈ-មាន ឬអាចនឹងមានការពាក់ព័ន្ធនឹងសកម្មភាពសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ឬការផ្តល់អាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណដល់បុគ្គលដាក់ពាក្យស្នើសុំអាចនឹងនាំឱ្យប៉ះពាល់សណ្តាប់ធ្នាប់ និងផលប្រយោជន៍សាធារណៈ។

៧- អភិបាល បុគ្គលិកជាន់ខ្ពស់ ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលុប របស់បុគ្គលដាក់ពាក្យស្នើសុំ÷

- មិនមានលក្ខណសម្បត្តិ និងអត្តចរិតល្អ
- បានប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងកិច្ចការពារវិនិយោគិន ឬអ្នកប្រើប្រាស់
- ធ្លាប់ប្រព្រឹត្តអំពើមិនស្មោះត្រង់ ឬធ្លាប់ប្រព្រឹត្តមិនត្រឹមត្រូវ ឬជាបុគ្គលអសមត្ថភាពក្នុងការផ្តល់សេវាហិរញ្ញវត្ថុ ឬការគ្រប់គ្រងក្រុមហ៊ុន
- បានធ្វើ ឬជាប់ពាក់ព័ន្ធនឹងអាជីវកម្មណាមួយផ្សេងទៀត ដែលធ្វើឱ្យមានការសង្ស័យ ចំពោះសមត្ថភាព និងសុក្រឹតភាពនៃសេចក្តីសម្រេចរបស់ខ្លួន
- បានធ្វើអាជីវកម្មដែលមានលក្ខណៈបោកបញ្ឆោត កេងប្រវ័ញ្ច ឬមិនត្រឹមត្រូវដោយប្រការណាមួយ
- ស្តែងចេញនូវភាពមិនអាចធ្វើសកម្មភាព ដើម្បីផលប្រយោជន៍របស់អត្ថគាហកៈ ឬបរធនបាលទាយក ដោយសារតែកេរ្តិ៍ឈ្មោះ បុគ្គលិកលក្ខណៈ សេចក្តីសុចរិតផ្នែកហិរញ្ញវត្ថុ និងភាពដែលអាចទុកចិត្តបានរបស់បុគ្គលទាំងនោះ
- ស្តែងចេញនូវភាពមិនអាចធ្វើសកម្មភាពក្រោមលក្ខខណ្ឌអាជ្ញាបណ្ណ ឬការអនុញ្ញាតប្រកបដោយប្រសិទ្ធភាព ភាពស្មោះត្រង់ និងយុត្តិធម៌
- ធ្លាប់ត្រូវបានប្រកាសក្ស័យធននៅក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំចុងក្រោយគិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។

លក្ខខណ្ឌមូលធនអប្បបរមាខាងលើនេះ មិនអនុវត្តចំពោះបុគ្គលដាក់ពាក្យស្នើសុំជាធនាគារពាណិជ្ជនៅព្រះរាជាណាចក្រកម្ពុជាទេ។ ដោយឡែក សម្រាប់ធនាគារពាណិជ្ជដែលស្នើសុំអាជ្ញាបណ្ណធ្វើប្រតិបត្តិការបរធនបាលកិច្ចត្រឹមតែការផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក (Escrow Services) លក្ខខណ្ឌតម្រូវក្នុងប្រការ១៦ នៃប្រកាសនេះ មិនត្រូវបានអនុវត្តទេ លើកលែងតែលក្ខខណ្ឌតម្រូវឱ្យមានប្រធានប្រតិបត្តិការ បុគ្គលិកជំនាញផ្នែកច្បាប់ និងគណនេយ្យករមានជំនាញបរធន ដែលត្រូវទទួលស្គាល់គុណវុឌ្ឍិពី **ន.ម.ឆ.**។

## ប្រការ១៧ .- បុគ្គលទទួលស្គាល់គុណវុឌ្ឍិក្នុងក្រុមហ៊ុនបរធនបាល

ដើម្បីទទួលបានការទទួលស្គាល់គុណវុឌ្ឍិ អភិបាល នាយកប្រតិបត្តិ ប្រធានប្រតិបត្តិការ បុគ្គលិកជំនាញផ្នែកច្បាប់ និងគណនេយ្យករមានជំនាញបរធន ត្រូវដាក់ពាក្យស្នើសុំមក **ន.ម.ឆ.** ទៅតាមទម្រង់ និងផ្តល់ឯកសារភ្ជាប់ ដែលកំណត់ដោយអគ្គនាយកនៃ **ន.ម.ឆ.** ព្រមទាំងបំពេញលក្ខខណ្ឌ ដូចខាងក្រោម÷

១- មានលក្ខណសម្បត្តិ និងអត្តចរិតល្អ។

២- ជាសមត្ថជន និងមានលំនៅឋានក្នុងព្រះរាជាណាចក្រកម្ពុជា។

៣- មានសញ្ញាបត្រ និងបទពិសោធន៍ការងារ ដូចខាងក្រោម÷

ក- អភិបាល និងនាយកប្រតិបត្តិ ត្រូវមានសញ្ញាបត្រយ៉ាងតិចកម្រិតឧត្តមសិក្សាពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ចឬហិរញ្ញវត្ថុ ឬសញ្ញាបត្រផ្សេងទៀត ដែលមានតម្លៃប្រហាក់ប្រហែលក្នុងវិស័យ



ស.ល

ហិរញ្ញវត្ថុ និងត្រូវមានចំណេះដឹង និងមានបទពិសោធន៍ការងារយ៉ាងតិច ៥ (ប្រាំ) ឆ្នាំ ក្នុងវិស័យបរធនបាលកិច្ចឬហិរញ្ញវត្ថុ។

ខ-ប្រធានប្រតិបត្តិការ ត្រូវមានសញ្ញាបត្រយ៉ាងតិចកម្រិតឧត្តមសិក្សាពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច ឬហិរញ្ញវត្ថុ ឬសញ្ញាបត្រផ្សេងទៀតដែលមានតម្លៃប្រហាក់ប្រហែលក្នុងវិស័យហិរញ្ញវត្ថុ និងត្រូវមានចំណេះដឹង និងបទពិសោធន៍ការងារយ៉ាងតិច ៣ (បី) ឆ្នាំក្នុងវិស័យបរធនបាលកិច្ច ឬហិរញ្ញវត្ថុ។

គ-បុគ្គលិកជំនាញផ្នែកច្បាប់ ត្រូវមានសញ្ញាបត្រយ៉ាងតិចកម្រិតឧត្តមសិក្សាផ្នែកច្បាប់ និងមានបទពិសោធន៍ការងារយ៉ាងតិច ៣ (បី) ឆ្នាំ ក្នុងវិស័យហិរញ្ញវត្ថុ។

ឃ-គណនេយ្យករមានជំនាញបរធន ត្រូវបំពេញលក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌដូចខាងក្រោម÷

-មានសញ្ញាបត្រយ៉ាងតិចកម្រិតឧត្តមសិក្សាផ្នែកគណនេយ្យ ឬផ្នែកពាក់ព័ន្ធនិងមានបទពិសោធន៍ការងារធ្វើជាគណនេយ្យករយ៉ាងតិច ៣(បី) ឆ្នាំ ក្នុងវិស័យបរធនបាលកិច្ច ឬហិរញ្ញវត្ថុ

-ជាគណនេយ្យករជំនាញ។

៤-ផ្តល់លិខិតតែងតាំងពីក្រុមហ៊ុនបរធនបាល។

៥-ចូលរួមវគ្គបណ្តុះបណ្តាល និងការប្រឡង ដែលរៀបចំដោយ **ន.ម.ឧ.** ឬដោយស្ថាប័នបណ្តុះបណ្តាលដែលទទួលបានសិទ្ធិពី **ន.ម.ឧ.** ហើយលទ្ធផលប្រឡងមានសុពលភាព ២ (ពីរ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទដែល **ន.ម.ឧ.** ប្រកាសលទ្ធផលប្រឡង។ បុគ្គលដាក់ពាក្យស្នើសុំត្រូវចូលរួមការអប់រំវិជ្ជាជីវៈបន្ត ដែលរៀបចំដោយ **ន.ម.ឧ.** ឬដោយស្ថាប័នបណ្តុះបណ្តាលដែលទទួលបានសិទ្ធិពី **ន.ម.ឧ.** មុនពេលលទ្ធផលប្រឡងអស់សុពលភាព។

៦-មិនស្ថិតនៅក្នុងស្ថានភាព ឬកាលៈទេសៈ ដូចមានចែងក្នុងចំណុច ក ដល់ ញ នៃកថាខណ្ឌទី២ នៃប្រការ ១៦ នៃប្រកាសនេះ។

លក្ខខណ្ឌគុណវុឌ្ឍិដូចមានចែងក្នុងប្រការនេះ មិនអនុវត្តចំពោះបរធនបាល ជាបុគ្គលសាធារណៈទាំងឡាយណាដែលតែងតាំងដោយរាជរដ្ឋាភិបាលនោះ។

## ប្រការ១៨ .- តួនាទី និងភារកិច្ចរបស់បុគ្គលិកជំនាញផ្នែកច្បាប់

បុគ្គលិកជំនាញផ្នែកច្បាប់មានតួនាទី និងភារកិច្ច ដូចខាងក្រោម÷

១-ផ្តល់ប្រឹក្សា និងត្រួតពិនិត្យឱ្យបានទៀងទាត់នូវអនុលោមភាពតាមច្បាប់ ដែលពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ក្រុមហ៊ុន និងការអនុវត្តការងាររបស់នាយកប្រតិបត្តិ និងផ្នែកផ្សេងៗ។

២-រក្សាទុក និងត្រួតពិនិត្យឡើងវិញនូវនីតិវិធីអនុលោមភាពតាមច្បាប់ សម្រាប់ផ្នែកនីមួយៗរបស់ក្រុមហ៊ុនបរធនបាល។

៣-ត្រួតពិនិត្យ និង/ឬឃ្លាំមើលភាពមិនប្រក្រតីទាំងឡាយ ដែលកើតមាននៅក្នុងប្រតិបត្តិការរបស់ក្រុមហ៊ុនបរធនបាល។ រាល់លទ្ធផល ដែលបានរកឃើញត្រូវរក្សាទុកជាឯកសារឱ្យបានត្រឹមត្រូវ។



ឥ.ល

ក្នុងករណីចាំបាច់ បុគ្គលិកជំនាញផ្នែកច្បាប់ត្រូវជូនដំណឹង និង/ឬប្រឹក្សាជាមួយបរធនបាលទាយក និង/ឬ **ន.ម.ឆ.**។

៤-ទទួលបន្ទុករៀបចំគោលការណ៍តាមដានការអនុវត្តសកម្មភាពប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ព្រមទាំងផ្តល់ការបណ្តុះបណ្តាលធ្វើបច្ចុប្បន្នកម្ម និង/ឬផ្តល់ប្រឹក្សាដល់ក្រុមហ៊ុនបរធនបាល និង/ឬសមាជិកនៃក្រុមប្រឹក្សាភិបាលអំពីបញ្ហាអនុលោមភាពតាមច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ និងការអភិវឌ្ឍបទប្បញ្ញត្តិ។

៥-ទទួលបន្ទុករៀបចំសៀវភៅមគ្គុទ្ទេសក៍អនុលោមភាពតាមច្បាប់ និងក្រមសីលធម៌វិជ្ជាជីវៈ សម្រាប់និយោជិតរបស់ក្រុមហ៊ុនបរធនបាល។ បុគ្គលិកជំនាញផ្នែកច្បាប់ត្រូវសហការជាមួយផ្នែកពាក់ព័ន្ធក្នុងការត្រួតពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នកម្មសៀវភៅមគ្គុទ្ទេសក៍អនុលោមភាពតាមច្បាប់ និងក្រមសីលធម៌វិជ្ជាជីវៈ។

៦-ត្រួតពិនិត្យ និងដោះស្រាយទំនាស់ផលប្រយោជន៍ផ្សេងៗ។

៧-រាយការណ៍ទៅក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការពាក់ព័ន្ធផ្សេងទៀតអំពីភាពមិនសមស្របនៃការគ្រប់គ្រង ចាត់ចែង និងថែរក្សាទ្រព្យសម្បត្តិបរធនបាលកិច្ចរបស់ក្រុមហ៊ុនបរធនបាល។

៨-តួនាទី និងភារកិច្ចផ្សេងទៀត ដែលអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១៩ .- វិធានប្រតិបត្តិការរបស់ក្រុមហ៊ុនបរធនបាល**

ក្រុមហ៊ុនបរធនបាលត្រូវមានវិធានប្រតិបត្តិការសមស្របដើម្បី÷

១-ចាត់ចែង គ្រប់គ្រង និងថែរក្សាសុវត្ថិភាពសាច់ប្រាក់ ឬទ្រព្យសម្បត្តិបរធនបាលកិច្ច។

២-គ្រប់គ្រងបរធនអនុលោមតាមលិខិតបរធនបាលកិច្ច គោលការណ៍ណែនាំ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

៣-ធានានូវភាពដាច់ដោយឡែកពីគ្នារវាងទ្រព្យសម្បត្តិបរធនបាលកិច្ច និងទ្រព្យសម្បត្តិផ្ទាល់របស់ក្រុមហ៊ុនបរធនបាល។

៤-កត់ត្រាភាពជាម្ចាស់កម្មសិទ្ធិ ឬសិទ្ធិ ដែលមានលើទ្រព្យសម្បត្តិបរធនបាលកិច្ច ចំណូលចំណាយ និងរាល់បំណុលដែលពាក់ព័ន្ធនឹងបរធនបាលកិច្ច សម្រាប់ការអនុវត្តគម្រោងផែនការនៃបរធនបាលកិច្ចនីមួយៗ។

៥-ត្រួតពិនិត្យផលប្រយោជន៍ផ្សេងៗ ដែលទទួលបានពីទ្រព្យសម្បត្តិបរធនបាលកិច្ច។

៦-បែងចែកផលប្រយោជន៍ផ្សេងៗដល់អត្ថគាហកៈ។

៧-ត្រួតពិនិត្យ និងទប់ស្កាត់ការគ្រប់គ្រងទ្រព្យសម្បត្តិបរធនបាលកិច្ច ដែលផ្ទុយពីបញ្ញត្តិក្នុងលិខិតបរធនបាលកិច្ច គោលការណ៍ណែនាំ និងបទប្បញ្ញត្តិពាក់ព័ន្ធ និងការចាត់ចែង និងគ្រប់គ្រងទ្រព្យសម្បត្តិបរធនបាលកិច្ចដែលមានភាពមិនស្មោះត្រង់។

**ប្រការ២០ .- ការតែងតាំង ឬផ្លាស់ប្តូរសមាសភាពក្រុមប្រឹក្សាភិបាល បុគ្គលទទួលស្គាល់គុណវុឌ្ឍិ និងបរធនបាលរូបវន្តបុគ្គលរបស់ក្រុមហ៊ុនបរធនបាល**

ក្រុមហ៊ុនបរធនបាល ត្រូវស្នើសុំការអនុញ្ញាតពីអគ្គនាយកនៃ **ន.ម.ឆ.** មុននឹងតែងតាំង ឬផ្លាស់ប្តូរសមាសភាពក្រុមប្រឹក្សាភិបាល អភិបាលទទួលស្គាល់គុណវុឌ្ឍិ នាយកប្រតិបត្តិ ប្រធានប្រតិបត្តិការ បុគ្គលិកជំនាញផ្នែកច្បាប់ គណនេយ្យករមានជំនាញបរធន និងបរធនបាលរូបវន្តបុគ្គល។ ប្រសិនបើតំណែងសម្រាប់បុគ្គលទទួលស្គាល់គុណវុឌ្ឍិ និងបរធនបាលរូបវន្តបុគ្គលនៅទំនេរ ក្រុមហ៊ុនបរធនបាលត្រូវជ្រើសរើសបេក្ខភាពថ្មីក្នុងរយៈពេលយ៉ាងយូរ ២ (ពីរ) ខែ គិតចាប់ពីកាលបរិច្ឆេទដែលតំណែងនោះនៅទំនេរ ឬក្នុងរយៈពេលសមស្របណាមួយដែលអនុញ្ញាតដោយអគ្គនាយកនៃ **ន.ម.ឆ.**។

**ប្រការ២១ .- ការលុបចោលអាជ្ញាបណ្ណ និង/ឬការអនុញ្ញាតរបស់ក្រុមហ៊ុនបរធនបាល**

អគ្គនាយកនៃ **ន.ម.ឆ.** អាចលុបចោលអាជ្ញាបណ្ណ និង/ឬការអនុញ្ញាតរបស់ក្រុមហ៊ុនបរធនបាលក្នុងករណីក្រុមហ៊ុនបរធនបាលស្នើសុំផ្អាក ឬឈប់ធ្វើប្រតិបត្តិការបរធនបាលកិច្ច។

## ផ្នែកទី៣

## ការទទួលបានអាជ្ញាបណ្ណជាបរធនបាលរូបវន្តបុគ្គល

**ប្រការ២២ .- អាជ្ញាបណ្ណបរធនបាលរូបវន្តបុគ្គល**

បរធនបាលរូបវន្តបុគ្គល អាចត្រូវផ្តល់អាជ្ញាបណ្ណជា÷

១-បរធនបាលរូបវន្តបុគ្គលឯករាជ្យនៃបរធនបាលកិច្ចបុគ្គល ឬបរធនបាលកិច្ចផ្សេងទៀត ឬ

២-បរធនបាលរូបវន្តបុគ្គលនៃក្រុមហ៊ុនបរធនបាល។

បរធនបាលរូបវន្តបុគ្គលដូចមានចែងក្នុងកថាខណ្ឌទី១ នៃប្រការនេះ ត្រូវបានកំណត់ និងស្នើសុំអាជ្ញាបណ្ណ និងបន្តអាជ្ញាបណ្ណ ដូចមានចែងក្នុងប្រការ១៥ នៃប្រកាសនេះ។

**ប្រការ២៣ .- ប្រតិបត្តិការបរធនបាលកិច្ចរបស់បរធនបាលរូបវន្តបុគ្គលឯករាជ្យ**

បរធនបាលរូបវន្តបុគ្គលឯករាជ្យ ដែលទទួលបានអាជ្ញាបណ្ណពីអគ្គនាយកនៃ **ន.ម.ឆ.** អាចធ្វើប្រតិបត្តិការបរធនបាលកិច្ចណាមួយ ដូចមានចែងក្នុងប្រការ១៣ នៃប្រកាសនេះ។ បរធនបាលរូបវន្តបុគ្គលឯករាជ្យ ដែលធ្វើប្រតិបត្តិការបរធនបាលកិច្ចដូចមានចែងក្នុងប្រការ១៣ នៃប្រកាសនេះ ដោយទ្រព្យសម្បត្តិបរធនបាលកិច្ចសរុបនៃបរធនបាលកិច្ចដែលគ្រប់គ្រង ចាត់ចែង និងថែរក្សា ដោយបរធនបាលរូបវន្តបុគ្គលឯករាជ្យម្នាក់មិនត្រូវលើសពី ១០.០០០.០០០.០០០ (ដប់ប៊ីលាន) រៀល ឬតាមការកំណត់របស់អគ្គនាយកនៃ **ន.ម.ឆ.**។

បរធនបាលរូបវន្តបុគ្គលឯករាជ្យអាចស្នើសុំធ្វើប្រតិបត្តិការបរធនបាលកិច្ច ដែលមានបរធនចុះបញ្ជីលើសពី ១០.០០០.០០០.០០០ (ដប់ប៊ីលាន) រៀល ក្នុងករណីដែលអគ្គនាយកនៃ **ន.ម.ឆ.** ពិនិត្យឃើញថា÷

-មានយន្តការធានាហានិភ័យប្រតិបត្តិការបរធនបាលកិច្ចសមស្រប

-មានធានារ៉ាប់រងវិជ្ជាជីវៈគ្រប់គ្រាន់ទៅតាមទំហំបរធនបាលកិច្ចនីមួយៗ

-បរធនដែលត្រូវចុះបញ្ជី ត្រូវបានថែរក្សាសុវត្ថិភាពនៅបុគ្គលថែរក្សាសុវត្ថិភាព ដែលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាតពី **គ.ម.ឧ.**

-មានយន្តការផ្សេងទៀតតាមការកំណត់របស់អគ្គនាយកនៃ **គ.ម.ឧ.**។

**ប្រការ២៤ ._ ការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ និងបន្តអាជ្ញាបណ្ណជាបរធនបាលរូបវន្តបុគ្គលឯករាជ្យ**

បុគ្គលដែលមានបំណងធ្វើជាបរធនបាលរូបវន្តបុគ្គលឯករាជ្យ ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ និងបន្តអាជ្ញាបណ្ណពី **គ.ម.ឧ.** ដូចមានចែងក្នុងប្រការ១៥ នៃប្រកាសនេះ។

**ប្រការ២៥ ._ ប្រតិបត្តិការបរធនបាលកិច្ចរបស់បរធនបាលរូបវន្តបុគ្គល**

បរធនបាលរូបវន្តបុគ្គលដែលទទួលបានអាជ្ញាបណ្ណអាចធ្វើប្រតិបត្តិការបរធនបាលកិច្ច ដូចខាងក្រោម÷

ក-បរធនបាលរូបវន្តបុគ្គលនៃក្រុមហ៊ុនបរធនបាល អាចធ្វើប្រតិបត្តិការ÷

-ធ្វើសកម្មភាពតាមការណែនាំរបស់ក្រុមហ៊ុនបរធនបាលពាក់ព័ន្ធនឹងប្រតិបត្តិការបរធនបាលកិច្ច ដូចមានចែងក្នុងប្រការ១៤ នៃប្រកាសនេះ ព្រមទាំងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ

-ធ្វើជាតំណាងក្រុមហ៊ុនបរធនបាល ស្របតាមការចាត់តាំងរបស់ក្រុមហ៊ុនបរធនបាល

-ធ្វើប្រតិបត្តិការ ឬសកម្មភាពផ្សេងទៀត ដែលអនុញ្ញាតដោយអគ្គនាយកនៃ **គ.ម.ឧ.**។

ខ-បរធនបាលរូបវន្តបុគ្គលឯករាជ្យ អាចធ្វើប្រតិបត្តិការបរធនបាលកិច្ច÷

-ធ្វើប្រតិបត្តិការបរធនបាលកិច្ច ដូចមានចែងក្នុងប្រការ១៣ និងប្រការ១៤ នៃប្រកាសនេះ

-ធ្វើប្រតិបត្តិការ ឬសកម្មភាពផ្សេងទៀត ដែលអនុញ្ញាតដោយអគ្គនាយកនៃ **គ.ម.ឧ.**។

**ប្រការ២៦ ._ លក្ខខណ្ឌតម្រូវអាជ្ញាបណ្ណបរធនបាលរូបវន្តបុគ្គល**

ដើម្បីទទួលបានអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណធ្វើជាបរធនបាលរូបវន្តបុគ្គល បុគ្គលដាក់ពាក្យស្នើសុំត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម÷

១-មានលក្ខណសម្បត្តិ និងអត្តចរិតល្អ។

២-ជាសមត្ថជន និងមានលំនៅឋានក្នុងព្រះរាជាណាចក្រកម្ពុជា។

៣-បំពេញលក្ខខណ្ឌយ៉ាងហោចណាស់មួយក្នុងចំណោមលក្ខខណ្ឌ សម្រាប់ធ្វើជាបរធនបាលរូបវន្តបុគ្គលនៃក្រុមហ៊ុនបរធនបាល ដូចខាងក្រោម÷

ក-មានសញ្ញាបត្រយ៉ាងតិចកម្រិតបរិញ្ញាបត្រពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុ ឬសញ្ញាបត្រផ្សេងទៀតដែលមានតម្លៃប្រហាក់ប្រហែលក្នុងវិស័យហិរញ្ញវត្ថុ ឬសេដ្ឋកិច្ច និងមានបទពិសោធន៍ការងារយ៉ាងតិចរយៈពេល ៣ (បី) ឆ្នាំ ក្នុងវិស័យហិរញ្ញវត្ថុ។

ខ-ជាអ្នកវិភាគហិរញ្ញវត្ថុជំនាញ (Certified Financial Analyst) ឬគណនេយ្យករជំនាញ (Certified Public Accountant) ដែលជាសមាជិកសកម្មរបស់វិទ្យាស្ថានគណនេយ្យករជំនាញ

ស.ជ

និងសវនករកម្ពុជា (**វ.គ.ស.ក.**) និងមានបទពិសោធន៍ការងារយ៉ាងតិចរយៈពេល ១ (មួយ) ឆ្នាំ ក្នុងវិស័យបរធនបាលកិច្ច ឬវិស័យហិរញ្ញវត្ថុ។

គ- ធ្លាប់ទទួលបានអាជ្ញាបណ្ណធ្វើជាបរធនបាលរូបវន្តបុគ្គល ក្នុងរយៈពេលយ៉ាងតិច ៣ (បី) ឆ្នាំ ពីយុត្តាធិការដែលទទួលស្គាល់ដោយ **ន.ម.ឌ.**។

៤- ផ្តល់លិខិតយល់ព្រមឱ្យធ្វើជាបរធនបាលរូបវន្តបុគ្គលពីក្រុមហ៊ុនបរធនបាល។

៥- បំពេញលក្ខខណ្ឌគុណវុឌ្ឍិដូចមានចែងក្នុងចំណុចទី៥ នៃកថាខណ្ឌទី១ នៃប្រការ១៧ នៃប្រកាសនេះ។

៦- មិនស្ថិតនៅក្រោមករណីណាមួយដូចខាងក្រោម÷

ក- មិនបានគោរពតាមសេចក្តីណែនាំផ្សេងៗ ដែលធ្វើឡើងដោយអនុលោមតាមប្រកាសនេះ។

ខ- ព័ត៌មាន ឬឯកសារ ដែលបុគ្គលដាក់ពាក្យស្នើសុំបានដាក់ជូន **ន.ម.ឌ.** មានលក្ខណៈក្លែងបន្លំ ឬនាំឱ្យយល់ខុស។

គ- មិនទូទាត់សងបំណុលតាមសេចក្តីសម្រេចរបស់តុលាការ។

ឃ- ធ្លាប់ធ្វើជាភាគហ៊ុនិក ដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលុប ឬបុគ្គលដែលមានទំនាក់ទំនងពិសេសជាមួយក្រុមហ៊ុនបរធនបាល ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស ឬគ្រឹះស្ថានហិរញ្ញវត្ថុណាមួយ ដែលធ្លាប់ត្រូវបានប្រកាសក្ស័យធននៅក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជាក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ ចុងក្រោយគិតត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ លើកលែងតែបុគ្គលដែលត្រូវបានទទួលស្គាល់ ដោយសេចក្តីសម្រេចរបស់តុលាការថា ពុំមានការទទួលខុសត្រូវចំពោះការក្ស័យធននេះ។

ង- ធ្លាប់ធ្វើជាភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលុប ឬបុគ្គលដែលមានទំនាក់ទំនងពិសេសជាមួយក្រុមហ៊ុនបរធនបាល ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស ឬគ្រឹះស្ថានហិរញ្ញវត្ថុ ដែលអាជ្ញាបណ្ណរបស់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ ឬគ្រឹះស្ថានហិរញ្ញវត្ថុនោះត្រូវបានដកហូតនៅក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជាក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ ចុងក្រោយ គិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ លើកលែងតែបុគ្គលដែលត្រូវបានទទួលស្គាល់ថា ពុំមានការទទួលខុសត្រូវចំពោះការដកហូតនេះ។

ច- បានប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងកិច្ចការពារវិនិយោគិន ឬអ្នកប្រើប្រាស់។

ឆ- ធ្លាប់ប្រព្រឹត្តអំពើមិនស្មោះត្រង់ ឬធ្លាប់ប្រព្រឹត្តមិនត្រឹមត្រូវ ឬជាបុគ្គលអសមត្ថភាពក្នុងការផ្តល់សេវាហិរញ្ញវត្ថុ ឬការគ្រប់គ្រងក្រុមហ៊ុន។

ជ- បានធ្វើ ឬជាប់ពាក់ព័ន្ធនឹងអាជីវកម្មណាមួយផ្សេងទៀត ដែលធ្វើឱ្យមានការសង្ស័យចំពោះសមត្ថភាព និងសុក្រឹតភាពនៃសេចក្តីសម្រេចរបស់ខ្លួន។

ឈ- បានធ្វើអាជីវកម្មដែលមានលក្ខណៈបោកបញ្ឆោត ឬកេងប្រវ័ញ្ច ឬមិនត្រឹមត្រូវដោយប្រការណាមួយ។

ឲ.ល

ញ- ស្តែងចេញនូវភាពមិនអាចធ្វើសកម្មភាព ដើម្បីផលប្រយោជន៍អតិថិជនរបស់ខ្លួន ដោយសារតែកេរ្តិ៍ឈ្មោះ បុគ្គលិកលក្ខណៈ សេចក្តីសុចរិតផ្នែកហិរញ្ញវត្ថុ និងភាពដែលអាចទុកចិត្តបានរបស់បុគ្គលទាំងនោះ។

ដ- ធ្លាប់ត្រូវបានប្រកាសក្ស័យធននៅក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំចុងក្រោយ គិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។

ឋ- ជាសមាជិកគណៈកម្មាធិការវិនិយោគរបស់គម្រោងវិនិយោគរួមដែលគ្រប់គ្រង និងចាត់ចែងដោយក្រុមហ៊ុនគ្រប់គ្រងមូលនិធិផ្សេងទៀត។

ឌ- ធ្លាប់បានទទួលអាជ្ញាបណ្ណពី **ន.ម.ឆ.** ដែលអាជ្ញាបណ្ណនោះត្រូវបានដកហូត ឬព្យួរទុក ឬធ្លាប់ប្រព្រឹត្តអំពើល្មើសដែលមានចែងក្នុងច្បាប់។

ឍ- ស្តែងចេញនូវភាពមិនអាចធ្វើសកម្មភាព ក្រោមលក្ខខណ្ឌអាជ្ញាបណ្ណប្រកបដោយប្រសិទ្ធភាព ភាពស្មោះត្រង់ និងយុត្តិធម៌។

ណ- មាន ឬអាចនឹងមានការពាក់ព័ន្ធនឹងសកម្មភាពលាងសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ឬការផ្តល់អាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណដល់បុគ្គលដាក់ពាក្យស្នើសុំ អាចនឹងនាំឱ្យប៉ះពាល់ផលប្រយោជន៍សាធារណៈ។

ត- ជាអភិបាល ជានិយោជិត ជាបរធនបាលរូបវន្តបុគ្គល ឬជាភ្នាក់ងារគ្រប់គ្រងមូលនិធិនៃក្រុមហ៊ុនគ្រប់គ្រងមូលនិធិ ឬក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស ឬក្រុមហ៊ុនបរធនបាលផ្សេងទៀត។

**ប្រការ២៧ .- លក្ខខណ្ឌតម្រូវអាជ្ញាបណ្ណធ្វើជាបរធនបាលរូបវន្តបុគ្គលឯករាជ្យ**

ដើម្បីទទួលបានអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណធ្វើជាបរធនបាលរូបវន្តបុគ្គលឯករាជ្យ បុគ្គលដាក់ពាក្យស្នើសុំត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម÷

១- លក្ខខណ្ឌដូចមានចែងក្នុងចំណុច៨, ៩, ១១, ១២, និង១៣ នៃប្រការ១៦ និងចំណុច១, ២, ៥, និង៦ នៃប្រការ២៦ នៃប្រកាសនេះ។

២- បំពេញលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌដូចខាងក្រោម សម្រាប់ធ្វើជាបរធនបាលរូបវន្តបុគ្គលឯករាជ្យ÷

ក- ជាមេធាវីដែលទទួលបានវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវីពីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងជាសមាការី (Associate) ឬជាសមាជិក (Member) នៃការិយាល័យ ឬក្រុមហ៊ុនមេធាវីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ខ- ជាសារការី ដែលទទួលបានការតែងតាំងពីរាជរដ្ឋាភិបាល ឬតែងតាំងដោយលិខិតបទដ្ឋានគតិយុត្ត ឬលិខិតរបស់ក្រសួងយុត្តិធម៌ និងជាសមាការី (Associate) ឬសមាជិកសារការី (Member) នៃមន្ទីរសារការីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

គ- ជាអភិបាលបណ្តោះអាសន្ន ដែលត្រូវបានចុះបញ្ជីទទួលស្គាល់ ដោយស្ថាប័នមានសមត្ថកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ឯ.ឋ

ឃ- ជាអភិបាលឯករាជ្យនៃក្រុមហ៊ុន ដែលមិនពាក់ព័ន្ធនឹងទំនាក់ទំនងផលប្រយោជន៍ជាមួយក្រុមហ៊ុនបរធនបាល ឬបរធនបាលទាយក ឬអត្ថគាហកៈនៃបរធនបាលកិច្ច។

ង- ធ្លាប់ជាប្រធានក្រុមប្រឹក្សាភិបាល ឬអភិបាល ឬនាយកប្រតិបត្តិ ឬប្រធានផ្នែកហិរញ្ញវត្ថុ ឬប្រធានប្រតិបត្តិការ ឬប្រធានសាខានៃក្រុមហ៊ុនណាមួយ។

ច- ធ្លាប់ទទួលបានអាជ្ញាបណ្ណ ឬការអនុញ្ញាតធ្វើជាបរធនបាលបុគ្គល ក្នុងរយៈពេលយ៉ាងតិច ៣ (បី) ឆ្នាំ ពីយុត្តាធិការដែលទទួលស្គាល់ដោយ **ន.ម.ឆ.**។

ឆ- ជាគណនេយ្យករជំនាញនៃក្រុមហ៊ុនសវនកម្ម។

ជ- ជាអ្នកវិភាគហិរញ្ញវត្ថុជំនាញ (Certified Financial Analyst) ឬគណនេយ្យករជំនាញ (Certified Public Accountant) ដែលជាសមាជិកសកម្មរបស់ **វ.គ.ស.ក.**។

ឈ- បុគ្គលធ្លាប់ទទួលបានអាជ្ញាបណ្ណធ្វើជាបរធនបាលរូបវន្តបុគ្គលដោយ **ន.ម.ឆ.**។

ញ- បុគ្គលធ្លាប់ទទួលបានអាជ្ញាបណ្ណធ្វើជាភ្នាក់ងារគ្រប់គ្រងមូលនិធិពីនិយ័តករមូលបត្រកម្ពុជា។

៣- បរធនបាលរូបវន្តបុគ្គលឯករាជ្យត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម÷

ក- ដាក់ប្រាក់តម្កល់ធានាអាជីវកម្មចំនួន ៨០.០០០.០០០ (ប៉ែតសិបលាន) រៀល ក្នុងគណនីរបស់ **ន.ម.ឆ.** នៅធនាគារជាតិនៃកម្ពុជា។

ខ- រក្សាទុកទ្រព្យសម្បត្តិបរធនបាលកិច្ច ឬតម្កល់មូលនិធិ សម្រាប់បរធនបាលកិច្ចនីមួយៗ នៅបុគ្គលថែរក្សាសុវត្ថិភាពដែលទទួលបានការអនុញ្ញាត និង/ឬការចុះបញ្ជីពីអគ្គនាយកនៃ **ន.ម.ឆ.** ឬក្រុមហ៊ុនបរធនបាល ដែលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាតពីអគ្គនាយកនៃ **ន.ម.ឆ.** ឬបុគ្គលផ្សេងទៀត ដែលបានការអនុញ្ញាតពីអគ្គនាយកនៃ **ន.ម.ឆ.**។ បែបបទ និងយន្តការរក្សាទុកទ្រព្យសម្បត្តិបរធនបាលកិច្ច ឬការតម្កល់មូលនិធិនេះ ត្រូវស្ថិតនៅក្រោមការកំណត់របស់ **ន.ម.ឆ.**។

## ប្រការ២៨ .- ការលុបចោលអាជ្ញាបណ្ណរបស់បរធនបាលរូបវន្តបុគ្គល

អគ្គនាយកនៃ **ន.ម.ឆ.** អាចលុបចោលអាជ្ញាបណ្ណបរធនបាលរូបវន្តបុគ្គល ក្នុងករណីបរធនបាលរូបវន្តបុគ្គល ស្ថិតក្នុងស្ថានភាពណាមួយ ដូចខាងក្រោម÷

១- ក្លាយជាអសមត្ថជន។

២- លាឈប់ ឬផ្លាស់ប្តូរការងារ។

៣- ត្រូវបានព្យួរ ដាក់កំហិត ឬដកហូតនីតិសម្បទាជាមេធាវី ឬសារការី ឬគណនេយ្យករជំនាញពីស្ថាប័នមានសមត្ថកិច្ច។

៤- ត្រូវបានរកឃើញដោយស្ថាប័នមានសមត្ថកិច្ច ឬតុលាការ ថាបានប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

៥- ហេតុការណ៍ណាមួយ ដែលបរធនបាលរូបវន្តបុគ្គលមិនអាចអនុវត្តការងារបាន។

ស.ធ

## ផ្នែកទី៤
## ភារកិច្ច និងការទទួលខុសត្រូវផ្សេងៗរបស់បរធនបាល

### ប្រការ២៩ .- ការចាប់ផ្តើមប្រតិបត្តិការបរធនបាលកិច្ច

បរធនបាលដែលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាត ត្រូវចាប់ផ្តើមធ្វើប្រតិបត្តិការបរធនបាលកិច្ច ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ខែ គិតចាប់ពីកាលបរិច្ឆេទចេញអាជ្ញាបណ្ណ និង/ឬការអនុញ្ញាត។

### ប្រការ៣០ .- ការបែងចែកប្រតិបត្តិការបរធនបាលកិច្ចរបស់បរធនបាល ដែលទទួលបានអាជ្ញាបណ្ណ និង/ឬ ការអនុញ្ញាត

បរធនបាលដែលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាត ត្រូវធ្វើប្រតិបត្តិការដែលទទួលបានការអនុញ្ញាតពីអគ្គនាយកនៃ **ន.ម.ធ.** ដាច់ដោយឡែកពីអាជីវកម្មផ្សេងដែលខ្លួនមាន ត្រូវមានទីតាំងអាជីវកម្ម បរិក្ខារ ប្រព័ន្ធព័ត៌មានវិទ្យា ធនធានមនុស្សដាច់ដោយឡែកពីគ្នា និងត្រូវមានរបាំងព័ត៌មាន(Chinese Wall) សមស្រប។

### ប្រការ៣១ .- ភារកិច្ចបន្តគោរពតាមលក្ខខណ្ឌ

ក្រុមហ៊ុនបរធនបាលដែលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាតត្រូវបន្តគោរពតាមលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ១៦ ប្រការ១៧ និងប្រការ១៩ នៃប្រកាសនេះ។

បរធនបាលរូបវន្តបុគ្គលនៃក្រុមហ៊ុនបរធនបាលដែលទទួលបានអាជ្ញាបណ្ណ ត្រូវបន្តគោរពតាមលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ២៥ និងប្រការ២៦ នៃប្រកាសនេះ។

បរធនបាលរូបវន្តបុគ្គលឯករាជ្យដែលទទួលបានអាជ្ញាបណ្ណ ត្រូវបន្តគោរពតាមលក្ខខណ្ឌដូចមានចែងក្នុងប្រការ២៣ ប្រការ២៥ ប្រការ២៦ និងប្រការ២៧ នៃប្រកាសនេះ។

បុគ្គលទទួលស្គាល់គុណវុឌ្ឍិ ត្រូវបន្តគោរពតាមលក្ខខណ្ឌដូចមានចែងក្នុងប្រការ១៧ នៃប្រកាសនេះ។

### ប្រការ៣២ .- ការលុបចោលការទទួលស្គាល់គុណវុឌ្ឍិ

អគ្គនាយកនៃ **ន.ម.ធ.** អាចលុបចោលការទទួលស្គាល់គុណវុឌ្ឍិ ក្នុងករណីបុគ្គលទទួលស្គាល់គុណវុឌ្ឍិ ស្ថិតក្នុងស្ថានភាពណាមួយ ដូចខាងក្រោម÷

១- ក្លាយជាអសមត្ថជន។

២- លាឈប់ ឬផ្លាស់ប្តូរការងារ។

៣- ត្រូវបានព្យួរ ដាក់កំហិត ឬដកហូតនីតិសម្បទាជាមេធាវី សារការី ឬគណនេយ្យករជំនាញពីស្ថាប័នមានសមត្ថកិច្ច។

៤- ត្រូវបានរកឃើញដោយស្ថាប័នមានសមត្ថកិច្ច ឬតុលាការថាបានប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

៥- មានហេតុការណ៍ណាមួយដែលបុគ្គលទទួលស្គាល់គុណវុឌ្ឍិមិនអាចអនុវត្តការងារបាន។

### ប្រការ៣៣ .- ភារកិច្ចរក្សាកម្រិតស្ថានភាពហិរញ្ញវត្ថុ

បរធនបាលដែលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាត ត្រូវរក្សាឱ្យបានគ្រប់ពេលវេលានូវកម្រិតសោធនភាព អនុបាតហានិភ័យ មូលធនសុទ្ធ និងកម្រិតស្ថានភាពហិរញ្ញវត្ថុផ្សេងទៀត ដែលកំណត់ដោយ **ន.ម.ធ.**។

ស.ឋ

### ប្រការ៣៤ .- ការបើក ឬបិទសាខា ឬការិយាល័យតំណាងរបស់បរធនបាលដែលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាត

បរធនបាលដែលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាតដែលមានបំណងបើក ឬបិទសាខា ឬការិយាល័យតំណាង ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតជាមុនពីអគ្គនាយកនៃ **ន.ម.ធ.** ដោយត្រូវបំពេញលក្ខខណ្ឌដែលកំណត់ដោយ **ន.ម.ធ.**។

### ប្រការ៣៥ .- ការជូនដំណឹងអំពីបុគ្គលទទួលស្គាល់គុណវុឌ្ឍិ និងបរធនបាលរូបវន្តបុគ្គលទទួលបានអាជ្ញាបណ្ណ

បរធនបាលដែលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាត ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមក **ន.ម.ធ.** អំពីការលាឈប់ ឬការបញ្ចប់តួនាទី ឬការផ្លាស់ប្តូរមុខងាររបស់បុគ្គលទទួលស្គាល់គុណវុឌ្ឍិ និងបរធនបាលរូបវន្តបុគ្គលដែលទទួលបានអាជ្ញាបណ្ណរបស់ខ្លួនក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីទទួលបានលិខិតលាឈប់ពីការងារ ឬការសម្រេចបញ្ចប់តួនាទី ឬការផ្លាស់ប្តូរមុខងាររបស់បុគ្គល និងបរធនបាលរូបវន្តបុគ្គលនៃក្រុមហ៊ុនបរធនបាលនោះ។

### ប្រការ៣៦ .- ការទទួលខុសត្រូវចំពោះសកម្មភាពរបស់បរធនបាលរូបវន្តបុគ្គលនៃក្រុមហ៊ុនបរធនបាល

ក្រុមហ៊ុនបរធនបាលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាតត្រូវ ត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់លើសកម្មភាពរបស់បរធនបាលរូបវន្តបុគ្គល ដែលបំពេញមុខងារក្នុងនាមក្រុមហ៊ុនបរធនបាលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាតនោះ។

ក្រុមហ៊ុនបរធនបាលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាត ត្រូវបង្កើត រក្សា និងតម្រូវឱ្យអនុវត្តនីតិវិធីជាលាយលក្ខណ៍អក្សរទាក់ទងនឹងការប្រព្រឹត្តនៃបរធនបាលរូបវន្តបុគ្គលរបស់ខ្លួន។

ក្រុមហ៊ុនបរធនបាលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាត ត្រូវទទួលខុសត្រូវផ្នែករដ្ឋប្បវេណីដែលកើតចេញពីសកម្មភាពរបស់បរធនបាលរូបវន្តបុគ្គលរបស់ខ្លួន ដែលទទួលបានការអនុញ្ញាតពីក្រុមហ៊ុនបរធនបាលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាត ឱ្យធ្វើសកម្មភាពក្រោមលក្ខខណ្ឌនៃអាជ្ញាបណ្ណ និង/ឬការអនុញ្ញាត។

សកម្មភាពរបស់បរធនបាលរូបវន្តបុគ្គលដែលទទួលបានអាជ្ញាបណ្ណ ដែលនាំឱ្យក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាតទទួលខុសត្រូវចំពោះបណ្តឹងរដ្ឋប្បវេណី រាប់បញ្ចូលទាំងការគេចវេះមិនចាត់វិធានការក្នុងស្ថានភាពជាក់ស្តែងណាមួយផងដែរ។

សកម្មភាពរបស់បរធនបាលរូបវន្តបុគ្គលទទួលបានអាជ្ញាបណ្ណ ដែលអនុញ្ញាតដោយក្រុមហ៊ុនបរធនបាលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាត ត្រូវគិតទាំងសកម្មភាពដែលទទួលបានការអនុញ្ញាតដោយតុណ្ហីភាពដោយឈរលើមូលដ្ឋាន ដែលក្រុមហ៊ុនបរធនបាលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាត ដឹង ឬគួរតែដឹងថា បរធនបាលរូបវន្តបុគ្គលទទួលបានអាជ្ញាបណ្ណនោះ បានធ្វើសកម្មភាពនានា ហើយមិនចាត់វិធានការដើម្បីទប់ស្កាត់ ឬបដិសេធសកម្មភាពទាំងនោះ។

ឡ.ជ

**ប្រការ៣៧ .- គោលការណ៍ខុត្តមានុវត្តន៍របស់បរធនបាល**

បរធនបាលត្រូវអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនប្រកបដោយសុចរិត ស្មោះត្រង់ ឯករាជ្យ មិនលម្អៀង តម្លាភាព គណនេយ្យភាព ព្រមទាំងប្រសិទ្ធភាព ដើម្បីធានានូវផលប្រយោជន៍របស់បរធនបាលទាយក និង អត្ថគាហកៈ។

**ប្រការ៣៨ .- ការគ្រប់គ្រងទំនាស់ផលប្រយោជន៍**

ក្រុមហ៊ុនបរធនបាលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាតតាមប្រកាសនេះ ត្រូវកំណត់ឱ្យបាន ច្បាស់ជាលាយលក្ខណ៍អក្សរនូវគោលនយោបាយស្ដីពីការបង្ការ និងការគ្រប់គ្រងទំនាស់ផលប្រយោជន៍។ គោលនយោបាយនេះ ត្រូវទទួលបានការអនុញ្ញាតពីក្រុមប្រឹក្សាភិបាល ឬគណៈកម្មាធិការ ដែលចាត់តាំងដោយ ក្រុមប្រឹក្សាភិបាល និងត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយនៅក្នុងក្រុមហ៊ុនបរធនបាល។

ក្រុមហ៊ុនបរធនបាលត្រូវជំរុញ និងតាមដានការអនុវត្តគោលនយោបាយនេះរបស់អភិបាល នាយកប្រតិបត្តិ ប្រធានផ្នែក និងបុគ្គលិកក្នុងតំណែងគ្រប់គ្រងទាំងអស់។

ទំនាស់ផលប្រយោជន៍នេះសំដៅដល់ទំនាស់ផលប្រយោជន៍ ដូចខាងក្រោម÷

១-រវាងបរធនបាលទាយកទាំងឡាយ ដែលបានបង្កើតបរធនបាលកិច្ចនៅក្រោមការគ្រប់គ្រង និងចាត់ចែង ដោយក្រុមហ៊ុនបរធនបាល និងបុគ្គលពាក់ព័ន្ធនឹងប្រតិបត្តិការបរធនបាលកិច្ច និងប្រតិបត្តិការរបស់ ក្រុមហ៊ុនបរធនបាល។

២-រវាងបរធនបាលកិច្ច និងបរធនបាលកិច្ចដែលខ្លួនគ្រប់គ្រង។

៣-រវាងអត្ថគាហកៈ និងអត្ថគាហកៈ។

បរធនបាលរូបវន្តបុគ្គលឯករាជ្យដែលទទួលបានអាជ្ញាបណ្ណតាមប្រកាសនេះ ត្រូវកំណត់ឱ្យបានច្បាស់ ជាលាយលក្ខណ៍អក្សរ ដូចមានចែងក្នុងកថាខណ្ឌទី៣ នៃប្រការនេះ។

ក្នុងករណីដែលបរធនបាលមួយប្រកបអាជីវកម្មផ្សេងពីប្រតិបត្តិការបរធនបាលកិច្ច ដែលទទួលបាន អាជ្ញាបណ្ណ និង/ឬការអនុញ្ញាតពី **ន.ម.ធ.** បរធនបាលនៃបរធនបាលកិច្ចនីមួយៗ ត្រូវមានទីតាំងអាជីវកម្ម បរិក្ខារ ប្រព័ន្ធព័ត៌មានវិទ្យា ធនធានមនុស្សដាច់ដោយឡែកពីគ្នារវាងអាជីវកម្មនីមួយៗ និងត្រូវមានរបាំងព័ត៌មាន (Chinese Wall) សមស្រប។

**ប្រការ៣៩ .- ការផ្សាយពាណិជ្ជកម្មរបស់បរធនបាល**

បរធនបាលដែលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាតតាមប្រកាសនេះ ដែលមានបំណងផ្សាយ ពាណិជ្ជកម្ម ត្រូវរៀបចំមាតិកា និងវិធីសាស្ត្របង្ហាញសមស្រប ដើម្បីឱ្យអតិថិជនអាចទទួលបានព័ត៌មានចាំបាច់ និងមានប្រយោជន៍សម្រាប់ការប្រើប្រាស់សេវាគ្រប់គ្រង ចាត់ចែង និងថែរក្សាទ្រព្យសម្បត្តិបរធនបាលកិច្ច ដោយបរធនបាល។

ការផ្សាយពាណិជ្ជកម្មដូចមានចែងក្នុងកថាខណ្ឌទី១ នៃប្រការនេះ ត្រូវគោរពតាមលក្ខខណ្ឌ ដូចខាង ក្រោម÷

ស្ល.ណ

១-មិនត្រូវមានព័ត៌មានមិនពិត ឬបំផ្លើស។

២-មិនត្រូវជំរុញអតិថិជនឱ្យប្រើប្រាស់សេវាកម្មរបស់បរធនបាល។

៣-មិនត្រូវថ្លែងបញ្ជិតបញ្ចៀងពាក់ព័ន្ធនឹង ឬធានាបាននូវ ប្រាក់ចំណេញពីការវិនិយោគ លើកលែងតែមានការអនុញ្ញាតពីអគ្គនាយកនៃ **ន.ម.ធ.**។

៤-ត្រូវមានប្រភពព័ត៌មានឱ្យបានច្បាស់លាស់ ដែលមានលក្ខណៈបច្ចុប្បន្នភាព និងគួរឱ្យទុកចិត្តក្នុងករណីប្រើប្រាស់ ឬយោងព័ត៌មាន ដែលផ្តល់ឱ្យដោយបុគ្គលផ្សេង។

៥-ព័ត៌មានដែលមិនមានលក្ខណៈប៉ះពាល់ដល់សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ។

## ប្រការ៤០ .- ការជូនដំណឹងអំពីការកែប្រែឯកសារ ឬព័ត៌មាន

បរធនបាលដែលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាត និងបុគ្គលដាក់ពាក្យស្នើសុំ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់មក **ន.ម.ធ.** ក្នុងករណីមានការកែប្រែឯកសារ ឬព័ត៌មានពាក់ព័ន្ធនឹងពាក្យស្នើសុំការអនុញ្ញាត ឬបន្តការអនុញ្ញាត។

## ប្រការ៤១ .- កាតព្វកិច្ចស្នើសុំការអនុញ្ញាតលើការប្រើប្រាស់ ការផ្លាស់ប្តូរ ឬការកែប្រែ

ក្រុមហ៊ុនបរធនបាលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាត ត្រូវស្នើសុំការអនុញ្ញាតជាមុនពីអគ្គនាយកនៃ **ន.ម.ធ.** មុននឹង÷

-ផ្លាស់ប្តូរ ឬកែប្រែលក្ខន្តិកៈក្រុមហ៊ុនរួមទាំងសមាសភាពក្រុមប្រឹក្សាភិបាល រចនាសម្ព័ន្ធភាគហ៊ុនិក ដើមទុន កម្មវត្ថុអាជីវកម្ម នាមករណ៍ ឬទីស្នាក់ការ

-ផ្លាស់ប្តូរ ឬកែប្រែសមាសភាពបរធនបាលរូបវន្តបុគ្គលនៃក្រុមហ៊ុនបរធនបាល

-ប្រើប្រាស់ ឬកែប្រែលាភការ ឬកម្រៃសេវាផ្សេងៗ។

បរធនបាលរូបវន្តបុគ្គលឯករាជ្យដែលទទួលបានអាជ្ញាបណ្ណ ត្រូវស្នើសុំការអនុញ្ញាតជាមុនពីអគ្គនាយកនៃ **ន.ម.ធ.** មុននឹងផ្លាស់ប្តូរអាសយដ្ឋាន ឬទីស្នាក់ការ ប្រើប្រាស់ឬកែប្រែលាភការ ឬកម្រៃសេវាផ្សេងៗ។

## ប្រការ៤២ .- កាតព្វកិច្ចផ្តល់របាយការណ៍

ក្រុមហ៊ុនបរធនបាលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាត ត្រូវដាក់ជូន **ន.ម.ធ.** នូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ក្រុមហ៊ុនបរធនបាល ដែលត្រូវបានធ្វើសវនកម្មរួចដោយសវនករឯករាជ្យដែលមានការអនុញ្ញាត ឬអាជ្ញាបណ្ណពីនិយ័តករគណនេយ្យនិងសវនកម្ម (**ន.គ.ស.**) និងដែលទទួលបានការទទួលស្គាល់ពី **ន.ម.ធ.** ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ខែ បន្ទាប់ពីបញ្ចប់ឆ្នាំសារពើពន្ធនីមួយៗ ឬក្នុងរយៈពេលសមស្របណាមួយដែលកំណត់ដោយអគ្គនាយកនៃ **ន.ម.ធ.** និងរបាយការណ៍សាមាយិក ព្រមទាំងរបាយការណ៍ផ្សេងទៀតតាមការកំណត់របស់អគ្គនាយកនៃ **ន.ម.ធ.**។

បរធនបាលត្រូវរៀបចំរបាយការណ៍គ្រប់គ្រងនៃទ្រព្យសម្បត្តិបរធនបាលកិច្ច ឱ្យដាច់ដោយឡែកពីទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់បរធនបាល ដូចមានកំណត់ក្នុងបទប្បញ្ញត្តិជាធរមាន។

ឡ.ជ

**ប្រការ៤៣ ._ ការផ្តល់មុខងារដល់តតិយជន**

បរធនបាលមិនអាចផ្តល់មុខងារដល់បុគ្គលណាមួយបានទេ លើកលែងតែទទួលបានការអនុញ្ញាតពីអគ្គនាយកនៃ **ន.ម.ធ.**។

បរធនបាលត្រូវទទួលខុសត្រូវចំពោះរាល់សកម្មភាពរបស់បុគ្គល ដែលទទួលមុខងារខាងក្រៅ។

បរធនបាលដែលមានបំណងផ្តល់មុខងារដូចមានចែងក្នុងប្រការ១៤ នៃប្រកាសនេះ ទៅឱ្យបុគ្គលរក្សាសុវត្ថិភាពដែលទទួលបានការអនុញ្ញាត និង/ឬចុះបញ្ជីពី **ន.ម.ធ.** ត្រូវស្នើសុំការអនុញ្ញាតជាមុនពីអគ្គនាយកនៃ **ន.ម.ធ.**។

**ប្រការ៤៤ ._ ការរក្សាទុកកំណត់ត្រា**

បរធនបាលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាតត្រូវរក្សាទុក និងថែទាំរាល់កំណត់ត្រា ឯកសារ ទិន្នន័យ ព្រមទាំងបញ្ជិកាគណនេយ្យរបស់ខ្លួន និងរបស់បរធនបាលកិច្ច ក្នុងរយៈពេលយ៉ាងតិច ១០ (ដប់) ឆ្នាំនៅទីកន្លែងដែលមានសុវត្ថិភាព និងអាចទាញយកប្រើប្រាស់បាន (ករណីក្នុងទម្រង់ជាឯកសារ ឬទិន្នន័យទន់)ហើយត្រូវជូនដំណឹងទៅ **ន.ម.ធ.** អំពីទីកន្លែងរក្សាទុកនោះ។

**ផ្នែកទី៥**

**កម្រៃសេវា**

**ប្រការ៤៥ ._ សោហ៊ុយនៃការផ្ទេរភាគហ៊ុន**

ក្រុមហ៊ុនបរធនបាលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាតត្រូវបង់សោហ៊ុយនៃការផ្ទេរភាគហ៊ុន ចំនួន ០,៥ (សូន្យក្បៀសប្រាំ) ភាគរយ នៃភាគហ៊ុនដែលបានផ្ទេរ ឬស្មើនឹង ៤០.០០០.០០០ (សែសិបលាន) រៀល ក្នុងករណីដែលធំជាងនេះ។

ក្រុមហ៊ុនបរធនបាលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាត ត្រូវបង់សោហ៊ុយដូចមានចែងក្នុងប្រការនេះ នៅពេលដាក់ពាក្យស្នើសុំការអនុញ្ញាតផ្ទេរភាគហ៊ុននៅ **ន.ម.ធ.**។

សោហ៊ុយនេះមិនត្រូវបានប្រគល់ជូនក្រុមហ៊ុនបរធនបាលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាតវិញឡើយ ទោះបីជាការស្នើសុំការអនុញ្ញាតផ្ទេរភាគហ៊ុននេះត្រូវបានបដិសេធក៏ដោយ។

**ប្រការ៤៦ ._ សោហ៊ុយនៃការបង្កើន និងបន្ថយដើមទុន**

រាល់ការបង្កើនដើមទុន ក្រុមហ៊ុនបរធនបាលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាត ត្រូវបង់សោហ៊ុយចំនួន ០,០៣ (សូន្យក្បៀសសូន្យបី) ភាគរយ នៃចំនួនទឹកប្រាក់ដែលសុំបង្កើន។

រាល់ការបន្ថយដើមទុន ក្រុមហ៊ុនបរធនបាលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាត ត្រូវបង់សោហ៊ុយចំនួន ១ (មួយ) ភាគរយ នៃចំនួនទឹកប្រាក់ដែលបន្ថយ។

ក្រុមហ៊ុនបរធនបាលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាត ត្រូវបង់សោហ៊ុយដូចមានចែងក្នុងប្រការនេះ នៅពេលដាក់ពាក្យស្នើសុំការអនុញ្ញាតបង្កើន ឬបន្ថយដើមទុននៅ **ន.ម.ធ.**។

សោហ៊ុយនេះមិនត្រូវបានប្រគល់ជូនក្រុមហ៊ុនបរធនបាលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាត វិញឡើយ ទោះបីជាការស្នើសុំការអនុញ្ញាតបង្កើន ឬបន្ថយដើមទុនត្រូវបានបដិសេធក៏ដោយ។

**ប្រការ៤៧ .- ថ្លៃពាក្យស្នើសុំ សោហ៊ុយសិក្សាសំណុំលិខិត និងថ្លៃអាជ្ញាបណ្ណ/ការអនុញ្ញាត/ការចុះបញ្ជី**

បុគ្គលដាក់ពាក្យស្នើសុំត្រូវបង់ថ្លៃពាក្យស្នើសុំ សោហ៊ុយសិក្សាសំណុំលិខិត និងថ្លៃអាជ្ញាបណ្ណ/ការអនុញ្ញាត/ការចុះបញ្ជី ទៅតាមករណីដូចខាងក្រោម÷

១-ចំពោះការស្នើសុំអាជ្ញាបណ្ណ/ការអនុញ្ញាត/ការចុះបញ្ជី ឬបន្តអាជ្ញាបណ្ណ/បន្តការអនុញ្ញាតធ្វើប្រតិបត្តិការជាក្រុមហ៊ុនបរធនបាល÷

-ថ្លៃពាក្យស្នើសុំអាជ្ញាបណ្ណ/ការអនុញ្ញាត/ចុះបញ្ជីចំនួន ២០.០០០(ម្ភៃពាន់) រៀល មួយច្បាប់

-សោហ៊ុយសិក្សាសំណុំលិខិតស្នើសុំអាជ្ញាបណ្ណចំនួន ៤.០០០.០០០(បួនលាន) រៀល

-សោហ៊ុយសិក្សាសំណុំលិខិតស្នើសុំការអនុញ្ញាតចំនួន ២.០០០.០០០(ពីរលាន) រៀល

-សោហ៊ុយសិក្សាសំណុំលិខិតស្នើសុំការចុះបញ្ជីចំនួន ១.០០០.០០០(មួយលាន) រៀល។

-ថ្លៃអាជ្ញាបណ្ណ÷

- សម្រាប់ប្រតិបត្តិការលើបរធនបាលកិច្ចសាធារណៈចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំដំបូង និង ៦០.០០០.០០០ (ហុកសិបលាន) រៀល សម្រាប់ការបន្តអាជ្ញាបណ្ណរយៈពេល ៣ (បី) ឆ្នាំ
- សម្រាប់ប្រតិបត្តិការលើបរធនបាលកិច្ចពាណិជ្ជកម្មចំនួន ៣០.០០០.០០០(សាមសិបលាន) រៀល សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំដំបូង និង ៤៥.០០០.០០០ (សែសិបប្រាំលាន) រៀល សម្រាប់ការបន្តអាជ្ញាបណ្ណរយៈពេល ៣ (បី) ឆ្នាំ
- សម្រាប់ប្រតិបត្តិការលើបរធនបាលកិច្ចសង្គមចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំដំបូង និង ៣០.០០០.០០០ (សាមសិបលាន) រៀល សម្រាប់ការបន្តអាជ្ញាបណ្ណរយៈពេល ៣ (បី) ឆ្នាំ
- សម្រាប់ប្រតិបត្តិការលើបរធនបាលកិច្ចបុគ្គលចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំដំបូង និង ៣០.០០០.០០០ (សាមសិបលាន) រៀល សម្រាប់ការបន្តអាជ្ញាបណ្ណរយៈពេល ៣ (បី) ឆ្នាំ។

-ថ្លៃការអនុញ្ញាត÷

- សម្រាប់ប្រតិបត្តិការលើបរធនបាលកិច្ចសាធារណៈចំនួន ១៦.០០០.០០០ (ដប់ប្រាំមួយលាន) រៀល សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំដំបូង និង ២៤.០០០.០០០ (ម្ភៃបួនលាន) រៀល សម្រាប់ការអនុញ្ញាតបន្តរយៈពេល ៣ (បី) ឆ្នាំ
- សម្រាប់ប្រតិបត្តិការលើបរធនបាលកិច្ចពាណិជ្ជកម្មចំនួន ១២.០០០.០០០ (ដប់ពីរលាន) រៀល សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំដំបូង និង ១៨.០០០.០០០ (ដប់ប្រាំបីលាន) រៀល សម្រាប់ការអនុញ្ញាតបន្តរយៈពេល ៣ (បី) ឆ្នាំ

ស.៤

- សម្រាប់ប្រតិបត្តិការលើបរធនបាលកិច្ចសង្គមចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំដំបូង និង ១២.០០០.០០០ (ដប់ពីរលាន) រៀល សម្រាប់ការអនុញ្ញាតបន្តរយៈពេល ៣ (បី) ឆ្នាំ
- សម្រាប់ប្រតិបត្តិការលើបរធនបាលកិច្ចបុគ្គលចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំដំបូង និង ១២.០០០.០០០ (ដប់ពីរលាន) រៀល សម្រាប់ការអនុញ្ញាតបន្តរយៈពេល ៣ (បី) ឆ្នាំ។

-ថ្លៃការចុះបញ្ជីជាប្រតិបត្តិករបរធនបាល/បុគ្គលថែរក្សាសុវត្ថិភាពបរធនចំនួន ៤.០០០.០០០ (បួនលាន) រៀល សម្រាប់រយៈពេល ១ (មួយ) ឆ្នាំ។

២-ចំពោះការស្នើសុំអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណធ្វើជាបរធនបាលរូបវន្តបុគ្គល÷

-ថ្លៃពាក្យស្នើសុំអាជ្ញាបណ្ណចំនួន ២០.០០០ (ម្ភៃពាន់) រៀល ក្នុងមួយច្បាប់

-សោហ៊ុយសិក្សាសំណុំលិខិតស្នើសុំអាជ្ញាបណ្ណចំនួន ៤០០.០០០ (បួនរយពាន់) រៀល។

-ថ្លៃអាជ្ញាបណ្ណ÷

- បរធនបាលរូបវន្តបុគ្គលនៃក្រុមហ៊ុនបរធនបាលចំនួន ២.០០០.០០០ (ពីរលាន) រៀល សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំដំបូង និងថ្លៃបន្តអាជ្ញាបណ្ណចំនួន ៣.០០០.០០០ (បីលាន) រៀល សម្រាប់រយៈពេល ៣ (បី) ឆ្នាំ។
- បរធនបាលរូបវន្តបុគ្គលឯករាជ្យចំនួន ១៦.០០០.០០០ (ដប់ប្រាំមួយលាន) រៀល សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំដំបូង និងថ្លៃបន្តអាជ្ញាបណ្ណចំនួន ២៤.០០០.០០០ (ម្ភៃបួនលាន) រៀល សម្រាប់រយៈពេល ៣ (បី) ឆ្នាំ។

៣-ចំពោះការស្នើសុំការទទួលស្គាល់គុណវុឌ្ឍិរបស់អភិបាល នាយកប្រតិបត្តិ ប្រធានប្រតិបត្តិការ បុគ្គលិកជំនាញផ្នែកច្បាប់ និងគណនេយ្យករជំនាញបរធន÷

-ថ្លៃពាក្យស្នើសុំការទទួលស្គាល់គុណវុឌ្ឍិចំនួន ២០.០០០ (ម្ភៃពាន់) រៀល ក្នុងមួយច្បាប់

-សោហ៊ុយសិក្សាសំណុំលិខិតចំនួន ២០០.០០០ (ពីររយពាន់) រៀល។

បុគ្គលដាក់ពាក្យស្នើសុំត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិត នៅពេលដាក់ពាក្យស្នើសុំនៅ **ន.ម.ធ.**។

ថ្លៃពាក្យស្នើសុំនិងសោហ៊ុយសិក្សាសំណុំលិខិតអនុលោមតាមប្រកាសនេះ មិនត្រូវបានប្រគល់ឱ្យបុគ្គលដាក់ពាក្យស្នើសុំវិញឡើយ ទោះបីជាការស្នើសុំត្រូវបានបដិសេធក៏ដោយ។

**ប្រការ៤៨ ._ សោហ៊ុយលើការស្នើសុំការអនុញ្ញាតលើការប្រើប្រាស់ ផ្លាស់ប្តូរ ឬកែប្រែផ្សេងៗ**

បរធនបាលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត ត្រូវបង់សោហ៊ុយលើការស្នើសុំការអនុញ្ញាតលើការប្រើប្រាស់ ការផ្លាស់ប្តូរ ឬការកែប្រែដូចមានចែងក្នុងប្រការ៤១ នៃប្រកាសនេះទៅតាមករណី ដូចខាងក្រោម÷

ឭ.ង

១-ចំពោះការស្នើសុំការអនុញ្ញាតលើការប្រើប្រាស់ ការផ្លាស់ប្តូរ ឬការកែប្រែផ្សេងៗរបស់បរធនបាល÷

ក- សម្រាប់ក្រុមហ៊ុនបរធនបាល÷

-សោហ៊ុយលើការស្នើសុំការអនុញ្ញាតចំនួន ១០០.០០០ (មួយរយពាន់) រៀល

-កម្រៃរដ្ឋបាលចំនួន ១០០.០០០ (មួយរយពាន់) រៀល។

លើកលែងតែសោហ៊ុយនៃការផ្ទេរភាគហ៊ុន និងសោហ៊ុយនៃការបង្កើន និងបន្ថយដើមទុន ដែលត្រូវអនុវត្តតាមប្រការ៤៦ និងប្រការ៤៧ នៃប្រកាសនេះ។

ខ- សម្រាប់បរធនបាលរូបវន្តបុគ្គល÷

-សោហ៊ុយលើការស្នើសុំការអនុញ្ញាតចំនួន ៤០.០០០ (សែសិបពាន់) រៀល

-សោហ៊ុយរដ្ឋបាលចំនួន ៤០.០០០ (សែសិបពាន់) រៀល។

បុគ្គលដាក់ពាក្យស្នើសុំត្រូវបង់ថ្លៃសោហ៊ុយលើការស្នើសុំការអនុញ្ញាត និងសោហ៊ុយរដ្ឋបាលនៅពេលដាក់ពាក្យស្នើសុំនៅ **ន.ម.ឌ.**។

សោហ៊ុយលើការស្នើសុំការអនុញ្ញាត និងកម្រៃរដ្ឋបាល អនុលោមតាមប្រកាសនេះ មិនត្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំវិញឡើយ ទោះបីជាការស្នើសុំត្រូវបានបដិសេធក៏ដោយ។

**ប្រការ៤៩ .- សោហ៊ុយពិគ្រោះយោបល់ផ្នែកច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងបរធនបាលកិច្ច**

រាល់ការពិគ្រោះយោបល់ផ្នែកច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងបរធនបាលកិច្ច ត្រូវបង់សោហ៊ុយរដ្ឋបាលចំនួន ៤០០.០០០ (បួនរយពាន់) រៀល។

បុគ្គលដាក់ពាក្យស្នើសុំពិគ្រោះយោបល់លើខ្លឹមសារច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធបរធនបាលកិច្ច ត្រូវបង់ថ្លៃសោហ៊ុយរដ្ឋបាលនៅពេលដាក់ពាក្យស្នើសុំនៅ **ន.ម.ឌ.**។

## ជំពូកទី៤

## វិធាននៃការគ្រប់គ្រងក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស និងបុគ្គលរក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ

**ប្រការ៥០ .- ការកំណត់ជាបរធនបាល**

ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស និងបុគ្គលរក្សាសុវត្ថិភាព ត្រូវបានចាត់ទុកថាជាបរធនបាល ស្របតាមច្បាប់ បទប្បញ្ញត្តិជាធរមាន និងប្រកាសនេះ។

**ប្រការ៥១ .- ការចុះបញ្ជីរបស់ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសនៃគម្រោងវិនិយោគរួម និងបុគ្គលរក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ**

ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសនៃគម្រោងវិនិយោគរួម និងបុគ្គលរក្សាសុវត្ថិភាព ដែលស្ថិតក្រោមនិយ័តកម្មរបស់និយ័តករមូលបត្រកម្ពុជា ត្រូវស្នើសុំចុះបញ្ជីនៅ **ន.ម.ឌ.** ស្របតាមគោលការណ៍ណែនាំរួមរបស់និយ័តករមូលបត្រកម្ពុជា និង **ន.ម.ឌ.**។

ម.ដ

**ប្រការ៥២ .- ការគ្រប់គ្រងប្រតិបត្តិការក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស និងបរធនវិនិយោគក្រោមគម្រោងវិនិយោគរួម**

ប្រតិបត្តិការក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស និងបរធនវិនិយោគក្រោមគម្រោងវិនិយោគរួម ក្នុងវិស័យមូលបត្រ និងការបង្កើត ត្រូវស្ថិតនៅក្រោមនិយ័តករមូលបត្រកម្ពុជា។

ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសនៃគម្រោងវិនិយោគរួម ត្រូវស្នើសុំការអនុញ្ញាតពីអគ្គនាយកនៃ **ន.ម.ធ.** ប្រសិនបើក្រុមហ៊ុនមានបំណងធ្វើប្រតិបត្តិការបរធនបាលកិច្ចផ្សេងក្រៅពីគម្រោងវិនិយោគរួមក្នុងវិស័យមូលបត្រ ស្របតាមគោលការណ៍ណែនាំរបស់និយ័តករមូលបត្រកម្ពុជា និង **ន.ម.ធ.**។ ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសនៃគម្រោងវិនិយោគរួម ដែលទទួលបានការអនុញ្ញាតធ្វើប្រតិបត្តិការបរធនបាលកិច្ចផ្សេងក្រៅពីគម្រោងវិនិយោគរួម ត្រូវញែកឱ្យដាច់ដោយឡែកពីគ្នានូវប្រតិបត្តិការក្រុមហ៊ុន និងបរធនវិនិយោគក្រោមគម្រោងវិនិយោគរួមពីប្រតិបត្តិការបរធនបាលកិច្ច និងទ្រព្យសម្បត្តិបរធនបាលកិច្ចក្រៅពីគម្រោងវិនិយោគរួម។

**ប្រការ៥៣ .- ការគ្រប់គ្រងប្រតិបត្តិការបុគ្គលរក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ និងទ្រព្យសម្បត្តិក្រោមគណនីរក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ**

ប្រតិបត្តិការបុគ្គលរក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ និងទ្រព្យសម្បត្តិក្រោមគណនីរក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ និងការបង្កើត ត្រូវស្ថិតនៅក្រោមនិយ័តករមូលបត្រកម្ពុជា។

បុគ្គលរក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ ត្រូវស្នើសុំការអនុញ្ញាតពីអគ្គនាយកនៃ **ន.ម.ធ.** ប្រសិនបើបុគ្គលនេះមានបំណងធ្វើប្រតិបត្តិការរក្សាសុវត្ថិភាពបរធនបាលកិច្ចផ្សេងក្រៅពីវិស័យមូលបត្រ ស្របតាមគោលការណ៍ណែនាំរបស់និយ័តករមូលបត្រកម្ពុជា និង **ន.ម.ធ.**។ បុគ្គលរក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រដែលទទួលបានការអនុញ្ញាតធ្វើប្រតិបត្តិការបរធនបាលកិច្ច ផ្សេងក្រៅពីវិស័យមូលបត្រ ត្រូវញែកឱ្យដាច់ដោយឡែកពីគ្នានូវប្រតិបត្តិការរបស់ខ្លួន និងទ្រព្យសម្បត្តិ ក្រោមគណនីរក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រពីប្រតិបត្តិការបរធនបាលកិច្ច និងទ្រព្យសម្បត្តិបរធនបាលកិច្ចក្រៅពីវិស័យមូលបត្រ។

## ជំពូកទី៥
## វិធាននៃការប្រព្រឹត្តទៅនៃបរធនបាលកិច្ច
### ផ្នែកទី១
### កិច្ចដំណើរការនៃបរធនបាលកិច្ច

**ប្រការ៥៤ .- ការចាប់ផ្ដើមបរធនបាលកិច្ច**

បរធនបាលកិច្ចដែលទទួលបានការអនុញ្ញាតឱ្យបង្កើត ពីអគ្គនាយកនៃ **ន.ម.ធ.** បរធនបាលត្រូវចាប់ផ្ដើមនីតិវិធីនៃការចុះបញ្ជីបរធនបាលកិច្ចនៅ **ន.ម.ធ.** ក្នុងរយៈពេលមិនលើសពី ៣ (បី) ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការអនុញ្ញាតឱ្យបង្កើតបរធនបាលកិច្ច។

បរធរនបាលកិច្ច ត្រូវចាត់ទុកថាមានសុពលភាពគិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីបរធនបាលកិច្ចតទៅ។

## ប្រការ៥៥ .- ការផ្ទេរទ្រព្យសម្បត្តិបរធនបាលកិច្ចទៅក្នុងបរធនបាលកិច្ច

បរធនបាលទាយក ត្រូវធ្វើការផ្ទេរបរធនទៅក្នុងបរធនបាលកិច្ច ដើម្បីឱ្យបរធនបាលចាប់ផ្តើមធ្វើការចាត់ចែង គ្រប់គ្រង និងថែរក្សាស្របតាមលិខិតបរធនបាលកិច្ច និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច។

## ប្រការ៥៦ .- ការចាត់ចែង ការគ្រប់គ្រង និងការថែរក្សាទ្រព្យសម្បត្តិបរធនបាលកិច្ច

ទ្រព្យសម្បត្តិបរធនបាលកិច្ច ដែលកាន់កាប់ដោយបរធនបាល មិនត្រូវបានចាត់ចែង ឬប្រើប្រាស់ដើម្បីទូទាត់បំណុលរបស់បរធនបាល ឬបំណុលរបស់បុគ្គលណាមួយឡើយ ទោះបីក្នុងគោលបំណងនៃការធ្វើបុនទីតិសម្បទា ការជម្រះបញ្ជីឬការរំលាយដោយស្ម័គ្រចិត្ត ឬនីតិវិធីក្ស័យធន ឬស្ថានភាពប្រហាក់ប្រហែលផ្សេងទៀតក៏ដោយ។

បរធនបាលត្រូវគ្រប់គ្រងកំណត់ត្រា ឬកំណត់សម្គាល់សង្ខេបអំពីទ្រព្យសកម្ម បំណុល ចំណូល ចំណាយ និងអត្ថប្រយោជន៍ផ្សេងៗ ដែលកើតចេញពីទ្រព្យសម្បត្តិបរធនបាលកិច្ចពាក់ព័ន្ធ តាមទម្រង់កំណត់ដោយអគ្គនាយកនៃ **ន.ម.ឆ.**។

## ប្រការ៥៧ .- ការចាត់ចែងវិនិយោគទ្រព្យសម្បត្តិបរធនបាលកិច្ច

បរធនបាលអាចចាត់ចែងវិនិយោគទ្រព្យសម្បត្តិបរធនបាលកិច្ចបាន ក្នុងករណី÷

-ទទួលបានការយល់ព្រមជាមុនពីបរធនបាលទាយក/អ្នកផ្តល់វិភាគទានបរធនបាលកិច្ច និងអត្ថគាហកៈ

-ទទួលបានលិខិតមិនជំទាស់ពីអគ្គនាយកនៃ **ន.ម.ឆ** និង

-ទទួលបានការអនុញ្ញាតឱ្យធ្វើការវិនិយោគពីអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ។

## ប្រការ៥៨ .- ការផ្លាស់ប្តូរ ឬតែងតាំងបន្ថែមនូវបរធនបាល ឬការតែងតាំងបរធនបាលជំនួស

បរធនបាលទាយក ឬបរធនបាល ត្រូវស្នើសុំការអនុញ្ញាតជាមុនពីអគ្គនាយកនៃ **ន.ម.ឆ.** មុននឹងផ្លាស់ប្តូរ ឬតែងតាំងបន្ថែមនូវបរធនបាល។

បរធនបាលទាយក ឬបរធនបាល ត្រូវជូនដំណឹងអំពីសំណើសុំផ្លាស់ប្តូរនេះ ដល់អត្ថគាហកៈ។ អត្ថគាហកៈ មានសិទ្ធិដាក់ពាក្យជំទាស់ចំពោះសំណើសុំផ្លាស់ប្តូរនេះ មកអគ្គនាយកនៃ **ន.ម.ឆ.** ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹង។

អគ្គនាយកនៃ **ន.ម.ឆ.** អាចអនុញ្ញាត ឬបដិសេធលើសំណើសុំផ្លាស់ប្តូរនេះ លុះត្រាតែលក្ខខណ្ឌតាមបញ្ញត្តិនៃមាត្រា២៥ នៃច្បាប់ ត្រូវបានបំពេញ និងបំពេញតាមនីតិវិធីពាក់ព័ន្ធ ដែលកំណត់ដោយអគ្គនាយកនៃ **ន.ម.ឆ.** ហើយការផ្លាស់ប្តូរនេះមិនប៉ះពាល់ដល់ផលប្រយោជន៍របស់អត្ថគាហកៈ។

អគ្គនាយកនៃ **ន.ម.ឆ.** អាចតម្រូវឱ្យបរធនបាលធ្វើការផ្សព្វផ្សាយសេចក្តីសម្រេចរបស់អគ្គនាយកនៃ **ន.ម.ឆ.** លើសំណើសុំផ្លាស់ប្តូរនេះតាមរយៈប្រព័ន្ធសារព័ត៌មាន ក្នុងករណីចាំបាច់។

## ប្រការ៥៩ .- កាតព្វកិច្ចរាយការណ៍ព័ត៌មានទាន់ពេល

បរធនបាលត្រូវជូនដំណឹងភ្លាមទៅអគ្គនាយកនៃ **ន.ម.ឆ.** នៅពេលបានដឹងអំពីគោលបំណង ឬព្រឹត្តិការណ៍ដែលអាចនាំឱ្យកើតមាន ឬកំពុងតែស្ថិតក្នុងស្ថានភាពដែលនាំឱ្យមានការផ្លាស់ប្តូរ ឬប្រែប្រួលដូចមានចែងក្នុងលិខិតបរធនបាលកិច្ចពាក់ព័ន្ធនឹង÷

។.ល

១-នីតិបុគ្គល/គម្រោងរបស់នីតិបុគ្គលណាមួយ ដែលទ្រព្យសម្បត្តិបរធនបាលកិច្ច ត្រូវបានចាត់ចែង/វិនិយោគជាមួយ÷

-មានការផ្ទេរ ឬប្រែប្រួលភាគហ៊ុនឬកម្មសិទ្ធិភាគហ៊ុនចំនួនចាប់ពី ៥ (ប្រាំ) ភាគរយ ឡើងទៅក្រោមរូបភាពជាការបោះផ្សាយលក់មូលបត្រជាសាធារណៈ ការផ្លាស់ប្តូរកម្មវត្ថុអាជីវកម្ម ការរំលាយបញ្ចូលគ្នា ការទិញយក និងទទួលកាន់កាប់បន្ត និងសំណើទិញផែនទី

-មានស្ថានភាពដែលឈានទៅរកការធ្វើបុននីតិសម្បទា ការជម្រះបញ្ជីដោយស្ម័គ្រចិត្ត ឬការរំលាយនីតិបុគ្គលតាមការស្ម័គ្រចិត្ត ការប្រកាសក្ស័យធនដោយតុលាការ

-មានការទទួលរងទណ្ឌកម្ម ការព្យួរ ការផ្អាកអាជីវកម្ម ឬសកម្មភាព ដោយអាជ្ញាធរមានសមត្ថកិច្ច។

២-មានការផ្លាស់ប្តូរណាមួយ ដែលអាចធ្វើឱ្យប៉ះពាល់ដល់បរធនបាលកិច្ច និង/ឬបរធនបាល ដូចខាងក្រោម÷

-ការផ្លាស់ប្តូររបៀបនៃការគ្រប់គ្រង ចាត់ចែង និងថែរក្សាទ្រព្យសម្បត្តិបរធនបាលកិច្ច ឬបរធនបាលកិច្ច។

-ការផ្លាស់ប្តូរក្នុងការពណិនា និងតម្លៃនៃទ្រព្យសម្បត្តិបរធនបាលកិច្ច ដែលស្ថិតនៅក្រោមការចាត់ចែង គ្រប់គ្រង និងថែរក្សាក្នុងបរធនបាលកិច្ច។

-ការផ្លាស់ប្តូរដែលនាំឱ្យមានការប្រែប្រួលដល់ស្ថានភាពហិរញ្ញវត្ថុ ឥណទាន ឬបំណុលផ្សេងៗនៃបរធនបាលកិច្ច ឬបរធនបាល។

-ការវាយតម្លៃដែលរកឃើញថា ការផ្លាស់ប្តូរទាំងនោះអាចមានផលប៉ះពាល់ជាសក្តានុពលដល់បរធនបាលកិច្ចដែលគ្រប់គ្រងដោយបរធនបាល និងរាល់សកម្មភាព ឬ

-វិធានការទាំងឡាយដែលបានធ្វើ ឬដែលនឹងត្រូវធ្វើដោយបរធនបាល ក្នុងការគ្រប់គ្រងការផ្លាស់ប្តូរទាំងនេះ។

**ប្រការ៦០ .- ការជូនដំណឹងអំពីបទល្មើស**

បរធនបាល ឬបរធនបាលកិច្ច ដែលទទួលបានការអនុញ្ញាត និង/ឬចុះបញ្ជីពី **ន.ម.ធ.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់ទៅ **ន.ម.ធ.** ÷

ក-ត្រូវបានចោទប្រកាន់ពីបទមជ្ឈិម ឬបទឧក្រិដ្ឋ ឬមានពិរុទ្ធភាព ឬត្រូវកាត់ឱ្យជាប់ទោស ដោយសារបទល្មើសដែលមានក្នុងច្បាប់ជាធរមាននៅក្នុងយុត្តាធិការណាមួយ

ខ-ស្ថិតក្នុងដំណើរការនៃការចោទទោសពាក់ព័ន្ធនឹងសកម្មភាពអាជីវកម្មណាមួយ ឬការប្រកបវិជ្ជាជីវៈនៃបរធនបាលកិច្ចក្នុងយុត្តាធិការណាមួយ

គ-ទទួលរងនូវពិន័យអន្តរការណ៍ ការព្យួរអាជ្ញាបណ្ណ ឬការដកហូត ឬបដិសេធអាជ្ញាបណ្ណ ដោយបញ្ញត្តិករ និយ័តករ ឬស្ថាប័នវិជ្ជាជីវៈក្នុងយុត្តាធិការណាមួយ ឬ

ឃ-យ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីទទួលបានការជូនដំណឹងអំពីការចុះធ្វើអធិការកិច្ច ឬការស៊ើបអង្កេតណាមួយ ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការ រួមទាំងការធ្វើអធិការកិច្ច ឬស៊ើបអង្កេតពាក់ព័ន្ធនឹងក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬការិយាល័យតំណាងរបស់ខ្លួនផងដែរ។

**ប្រការ៦១ ._ ការត្រួតពិនិត្យប្រតិបត្តិការបរធនបាលកិច្ច/ប្រតិបត្តិករបរធនបាល**

ប្រតិបត្តិករបរធនបាល ដែលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាត និងបរធនបាលកិច្ច ដែលទទួលបានការអនុញ្ញាតបង្កើត និងចុះបញ្ជីពី **ន.ម.ឩ.** ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ **ន.ម.ឩ.**។

**ប្រការ៦២ ._ ការចុះធ្វើអធិការកិច្ច**

អគ្គនាយកនៃ **ន.ម.ឩ.** អាចចាត់មន្ត្រីអធិការកិច្ចបរធនបាលកិច្ចឱ្យចុះធ្វើអធិការកិច្ចទៅលើ÷

១-បរធនបាលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាត÷

-ចុះតាមដាន ឆែកឆេរ ចាប់យកវត្ថុតាង និងប្រមូលព័ត៌មានឬទិន្នន័យ ដែលជាប់សង្ស័យថាមានពាក់ព័ន្ធនឹងអំពើល្មើសក្នុងវិស័យបរធនបាលកិច្ច ដើម្បីពង្រឹងការអនុវត្តច្បាប់ក្នុងវិស័យបរធនបាលកិច្ច ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

២-ការប្រព្រឹត្តទៅនៃបរធនបាលកិច្ច÷

-ចុះត្រួតពិនិត្យ តាមដាន ឆែកឆេរ ចាប់យកវត្ថុតាង កោះហៅបុគ្គលពាក់ព័ន្ធ ព្រមទាំងឃាត់ខ្លួនជនសង្ស័យ និងប្រមូលព័ត៌មាន ឬទិន្នន័យ ដែលជាប់សង្ស័យថាប្រតិបត្តិការបរធនបាលកិច្ចមានពាក់ព័ន្ធនឹងការប្រព្រឹត្តល្មើស ឬសកម្មភាពលាងសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ

-ចុះត្រួតពិនិត្យ តាមដាន ឆែកឆេរ កោះហៅ ព្រមទាំងឃាត់ខ្លួនជនសង្ស័យ និងប្រមូលព័ត៌មាន ឬទិន្នន័យ ដែលជាប់សង្ស័យថាទ្រព្យសម្បត្តិបរធនបាលកិច្ច ត្រូវបានចាត់ចែង គ្រប់គ្រង និងថែរក្សាខុសពីលិខិតបរធនបាលកិច្ច ឬខុសច្បាប់និងបទប្បញ្ញត្តិក្នុងវិស័យបរធនបាលកិច្ច។

បរធនបាលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាតត្រូវផ្តល់កិច្ចសហការ ឯកសារ ព័ត៌មាន និង/ឬទិន្នន័យដល់មន្ត្រីអធិការកិច្ចបរធនបាលកិច្ច ដែលត្រូវចាត់តាំងដោយអគ្គនាយកនៃ **ន.ម.ឩ.** ដើម្បីចុះធ្វើអធិការកិច្ច។

## ផ្នែកទី២
## ការបញ្ចប់បរធនបាលកិច្ច

**ប្រការ៦៣ ._ លក្ខខណ្ឌនៃការបញ្ចប់បរធនបាលកិច្ច**

បរធនបាលកិច្ច ត្រូវបានបញ្ចប់ក្នុងករណី ដូចខាងក្រោម÷

១-ការមកដល់នៃកាលាវសានដែលកំណត់នៅក្នុងលិខិតបរធនបាលកិច្ច

២-បានសម្រេចគោលបំណងរបស់បរធនបាលកិច្ច

៣-ការសម្រេចដោយឯកច្ឆន្ទានុសិទ្ធិ ឬមតិជាឯកច្ឆន្ទរបស់បរធនបាលទាយក

៤-តាមសេចក្តីសម្រេចរបស់តុលាការមានសមត្ថកិច្ច ឬ

៥-តាមករណីផ្សេងទៀតដូចមានចែងក្នុងលិខិតបរធនបាលកិច្ច។

ឡ.ង

**ប្រការ៦៤ .- កាលាវសាននៃបរធនបាលកិច្ច**

បរធនបាលកិច្ច ត្រូវមានរយៈពេលអតិបរមាមិនលើសពី ១០០ ឆ្នាំ ចាប់ពីកាលបរិច្ឆេទ នៃការបង្កើត បរធនបាលកិច្ច។ លើកលែងតែបរធនបាលកិច្ចសង្គម និងបរធនបាលកិច្ចសាធារណៈ ឬបរធនបាលកិច្ចផ្សេងទៀតដែលត្រូវបានបង្កើតឡើងដោយច្បាប់ឬបទប្បញ្ញត្តិ បរធនបាលកិច្ចអាចមានរយៈពេលមិនកំណត់ ឬមានរយៈពេល ស្របតាមការកំណត់ដោយច្បាប់ ឬបទប្បញ្ញត្តិជាធរមាននោះ។

ក្នុងករណី បរធនបាលកិច្ចណាមួយមិនត្រូវបានកំណត់រយៈពេល ឬកាលាវសាន បរធនបាលកិច្ចនោះ អាចបន្តរហូតដល់ ១០០ ឆ្នាំ ក្រោយកាលបរិច្ឆេទនៃការបង្កើតបរធនបាលកិច្ចនោះ។ ចំពោះបរធនបាលកិច្ច ដែលបានកំណត់អំពីយន្តការកាលាវសាន បរធនបាលកិច្ចនោះ ត្រូវបន្តរហូតដល់កាលបរិច្ឆេទណាមួយខាង ក្រោមមកដល់មុន÷

១-កាលបរិច្ឆេទដែលកំណត់យន្តការនោះមកដល់ ឬ

២-កាលបរិច្ឆេទនៃរយៈពេល ១០០ ឆ្នាំ ក្រោយការបង្កើតបរធនបាលកិច្ចនោះមកដល់។

**ប្រការ៦៥ .- អានុភាពនៃការបញ្ចប់បរធនបាលកិច្ច**

បរធនបាលត្រូវជូនដំណឹងទៅ **ន.ម.ឧ.** យ៉ាងតិចបំផុត ៣០ (សាមសិប) ថ្ងៃ មុនកាលបរិច្ឆេទកាលាវសាននៃបរធនបាលកិច្ច ដែលស្ថិតនៅក្រោមការគ្រប់គ្រង ថែរក្សាសុវត្ថិភាព និងចាត់ចែងរបស់ខ្លួន។

មុននឹងដាក់ឱ្យបញ្ចប់បរធនបាលកិច្ច បរធនបាលត្រូវស្នើសុំអគ្គនាយកនៃ **ន.ម.ឧ.** ដើម្បីធ្វើការជម្រះបញ្ជីបរធនបាលកិច្ចតាមបែបបទ និងនីតិវិធី ដែលកំណត់ដោយ **ន.ម.ឧ.**។

បន្ទាប់ពីជម្រះបញ្ជីបរធនបាលកិច្ច បរធនបាលត្រូវ÷

១-ផ្ទេររាល់ទ្រព្យសម្បត្តិបរធនបាលកិច្ចដែលនៅសល់ ស្របតាមលក្ខខណ្ឌនៃបរធនបាលកិច្ច

២-ផ្ទេរទ្រព្យសម្បត្តិបរធនបាលកិច្ចទាំងអស់ ទៅអត្ថគាហកៈដែលនៅមានជីវិតរស់នៅទាំងអស់ក្នុងចំណែកស្មើៗគ្នា ក្នុងករណីដែលបរធនបាលកិច្ចនោះមិនកំណត់អំពីបុគ្គល ដែលត្រូវទទួលទ្រព្យសម្បត្តិ បរធនបាលកិច្ចនោះទេ។

**ប្រការ៦៦ .- ភារកិច្ចរបស់បរធនបាលក្នុងការប្រគល់ឯកសារ**

បរធនបាលដែលត្រូវបញ្ចប់ភារកិច្ចរបស់ខ្លួន ត្រូវផ្តល់ឱ្យបរធនបាលជំនួស ឬបរធនបាល ដែលកំពុងស្ថិតក្នុងភារកិច្ច នូវសំណុំឯកសារពាក់ព័ន្ធទាំងឡាយដែលខ្លួនបានកាន់កាប់កន្លងមក។

## ជំពូកទី៦

## ទោសប្បញ្ញត្តិ

**ប្រការ៦៧ .- វិធានការរដ្ឋបាល**

បរធនបាលដែលមិនអនុវត្តតាមលក្ខខណ្ឌតម្រូវនៃអាជ្ញាបណ្ណ/ការអនុញ្ញាត/ការចុះបញ្ជី ដូចមានចែងក្នុងប្រកាសនេះ ត្រូវទទួលរងវិធានការរដ្ឋបាលពីមន្ត្រីអធិការកិច្ចបរធនបាលកិច្ច ដូចខាងក្រោម÷

-ការព្រមាន

ឥ.ឲ

- ការដឹកនាំកែតម្រង់
- ការដាក់កំហិតលើអាជ្ញាបណ្ណ/ ការអនុញ្ញាត/ ការចុះបញ្ជី
- ការព្យួរអាជ្ញាបណ្ណ/ ការអនុញ្ញាត/ ការចុះបញ្ជី
- ការដកហូតអាជ្ញាបណ្ណ/ ការអនុញ្ញាត/ ការចុះបញ្ជី។

**ប្រការ៦៨._ ការផាកពិន័យ**

ត្រូវផាកពិន័យជាប្រាក់ពី ៤០០.០០០ (បួនរយពាន់) រៀល ទៅ ២៤.០០០.០០០ (ម្ភៃបួនលាន) រៀល ដោយមន្ត្រីអធិការកិច្ចបរធនបាលកិច្ច ចំពោះបរធនបាល ដែលមិនបានដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណមក **ន.ម.ធ.** ដូចមានចែងក្នុងប្រការ២៤ នៃប្រកាសនេះ។

ត្រូវផាកពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៦០.០០០.០០០ (ហុកសិបលាន) រៀល ដោយមន្ត្រីអធិការកិច្ចបរធនបាលកិច្ច ចំពោះបរធនបាលដែលមិនអនុវត្តតាមលក្ខខណ្ឌ ដូចមានចែងក្នុងកថាខណ្ឌទី២ នៃប្រការ១៥ ឬប្រការ៣៥ នៃប្រកាសនេះ។

ត្រូវផាកពិន័យជាប្រាក់ ពី ៥០.០០០.០០០ (ហាសិបលាន) រៀល ទៅ ២០០.០០០.០០០ (ពីររយលាន) រៀល ដោយមន្ត្រីអធិការកិច្ចបរធនបាលកិច្ច ចំពោះបរធនបាលដែលមិនរក្សាទុក និងថែទាំរាល់កំណត់ត្រា ឯកសារ ទិន្នន័យ ព្រមទាំងបញ្ជិកាគណនេយ្យពាក់ព័ន្ធនឹងបរធនបាលកិច្ច ដូចមានចែងក្នុងប្រការ៤៤ នៃប្រកាសនេះ។

ត្រូវផាកពិន័យជាប្រាក់ពី ៥០.០០០.០០០ (ហាសិបលាន) រៀល ទៅ ២០០.០០០.០០០ (ពីររយលាន) រៀល ដោយមន្ត្រីអធិការកិច្ចបរធនបាលកិច្ច ចំពោះបរធនបាលដែលមិនអនុវត្តតាមលក្ខខណ្ឌ ដូចមានចែងក្នុងកថាខណ្ឌទី១នៃប្រការ៥៦ ឬចំណុចទី២នៃប្រការ៥៩ នៃប្រកាសនេះ។

ត្រូវរងវិធានការរដ្ឋបាលណាមួយដូចមានចែងក្នុងប្រការ៦៧ នៃប្រកាសនេះ ដោយមន្ត្រីអធិការកិច្ចបរធនបាលកិច្ចបន្ថែមលើការផាកពិន័យដែលមានចែងក្នុងកថាខណ្ឌទី១ ទី២ ទី៣ និងទី៤ ខាងលើ ចំពោះបរធនបាល ដែលបានប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងកថាខណ្ឌទី១ ទី២ ទី៣ និងទី៤ ខាងលើនេះ។

ក្នុងករណីនៅតែបន្តប្រព្រឹត្តអំពីល្មើសដដែល ត្រូវទទួលរងការផាកពិន័យជាប្រាក់ដោយមន្ត្រីអធិការកិច្ចបរធនបាលកិច្ច ចំនួនទ្វេដងនៃទឹកប្រាក់ផាកពិន័យលើកមុន។

ការគ្រប់គ្រងប្រាក់ផាកពិន័យ ត្រូវអនុវត្តតាមបទប្បញ្ញត្តិជាធរមាន។

បទប្បញ្ញត្តិនៃជំពូកទោល (បទប្បញ្ញត្តិទូទៅ) នៃមាតិកាទី១ (បទប្បញ្ញត្តិទូទៅ) ជំពូកទោល (ការបង្ខំដល់រូបរាងកាយ) នៃមាតិកាទី៣ (ការបង្ខំដល់រូបរាងកាយ) នៃគន្ថីទី៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវយកមកអនុវត្តក្នុងករណីដែលសេចក្តីសម្រេចអំពីការផាកពិន័យបានចូលជាស្ថាពរ។

**ប្រការ៦៩._ បែបបទ នីតិវិធី និងការប្តឹងតវ៉ាចំពោះវិធានការរដ្ឋបាល និងការផាកពិន័យ**

បែបបទ និងនីតិវិធីនៃការចាត់វិធានការរដ្ឋបាល និងការផាកពិន័យដូចមានចែងក្នុងជំពូកនេះ ត្រូវកំណត់ដោយប្រកាសរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

ស.ជ

បុគ្គលដែលរងឥទ្ធិពលដោយផ្ទាល់ពីសេចក្ដីសម្រេចរបស់មន្ត្រីអធិការកិច្ចបរធនបាលកិច្ច ដូចមានចែងក្នុងជំពូកនេះ អាចប្ដឹងតវ៉ាតាមនីតិវិធីដូចមានចែងក្នុងច្បាប់ស្ដីពីបរធនបាលកិច្ច។

**ប្រការ៧០.- ការអនុវត្តច្បាប់ព្រហ្មទណ្ឌ និងច្បាប់ផ្សេងទៀត**

វិធានការរដ្ឋបាល និងការដាក់ពិន័យដូចមានចែងក្នុងជំពូកនេះ មិនរារាំងការអនុវត្តច្បាប់ព្រហ្មទណ្ឌជាធរមាន និងដោយមិនទាន់គិតដល់សំណងនៃការខូចខាតផ្សេងទៀត។

## ជំពូកទី៧
## អន្តរប្បញ្ញត្តិ

**ប្រការ៧១ .- ការស្នើសុំអាជ្ញាបណ្ណ និង/ឬការអនុញ្ញាតរបស់បរធនបាលនៃបរធនបាលកិច្ច ដែលបានចុះបញ្ជី**

បរធនបាលដែលគ្រប់គ្រង ចាត់ចែង និងថែរក្សាសុវត្ថិភាពទ្រព្យសម្បត្តិបរធនបាលកិច្ចដែលបានចុះបញ្ជីមុនប្រកាសនេះ ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ និង/ឬការអនុញ្ញាត ដោយបំពេញតាមបែបបទ និងនីតិវិធីនិយ័តកម្មតាមការកំណត់របស់ **ន.ម.ឆ.** ដោយអនុលោមតាមប្រកាសនេះ ក្នុងរយៈពេលយ៉ាងយូរ ៦ (ប្រាំមួយ) ខែ ជាកំហិតគិតចាប់ពីប្រកាសនេះ ចូលជាធរមាន។

ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសនៃគម្រោងវិនិយោគរួម បុគ្គលរក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត/ការទទួលស្គាល់ពីនិយ័តករមូលបត្រកម្ពុជា ត្រូវស្នើសុំចុះបញ្ជីនៅ **ន.ម.ឆ.** ដោយអនុលោមតាមប្រកាសនេះ ក្នុងរយៈពេលយ៉ាងយូរ ៦ (ប្រាំមួយ) ខែ ជាកំហិតគិតចាប់ពីប្រកាសនេះ ចូលជាធរមាន។

**ប្រការ៧២ .- ការស្នើសុំចុះបញ្ជីបរធនបាលកិច្ចដែលបានបង្កើតនិងកំពុងធ្វើប្រតិបត្តិការ**

បរធនបាលទាយក ដែលបានបង្កើតបរធនបាលកិច្ច ហើយមិនទាន់បានចុះបញ្ជីបរធនបាលកិច្ចនៅ **ន.ម.ឆ.** ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីបរធនបាលកិច្ច ដោយបំពេញបែបបទនិងនីតិវិធីតាមការកំណត់របស់ **ន.ម.ឆ.** ដោយអនុលោមតាមប្រកាសនេះ ក្នុងរយៈពេលយ៉ាងយូរ ៦ (ប្រាំមួយ) ខែ ជាកំហិត គិតចាប់ពីប្រកាសនេះចូលជាធរមាន។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**ប្រការ៧៣ .- គោលការណ៍ណែនាំ**

អគ្គនាយកនៃ **ន.ម.ឆ.** អាចចេញគោលការណ៍ណែនាំ អនុលោមតាមច្បាប់ស្ដីពីបរធនបាលកិច្ច អនុក្រឹត្យស្ដីពីការចុះបញ្ជីបរធនបាលកិច្ច និងប្រកាសនេះដើម្បីសម្រួលដល់ការយល់ដឹង និងការអនុវត្តតាមប្រកាសនេះ។

**ប្រការ៧៤ ._ បដិវាទកម្ម**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧៥ ._ ការអនុវត្ត**

អគ្គនាយកនៃ **ន.ម.ធ.** ប្រធាននាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច គ្រប់ប្រធាននាយកដ្ឋានស្ថិតនៅចំណុះឱ្យ **ន.ម.ធ.** និងបុគ្គលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះតាមភារកិច្ចរៀងខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ពុធ ៩ រោច ខែ បុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ធនាគារជាតិនៃកម្ពុជា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អនុប្រធាន និងសមាជិកក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៧៥

  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ